# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

LIBRARY

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

INSTITUT BOUDDHIQUE

ឆ្នាំទី ២៧ ខែកក្កដា លេខ ៧

ព.ស. ២៤៩៨ – គ.ស. ១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* *ទំព័រ*

— ធម្មានុធម្មប្បដិបត្តិកថា .......... ព្រះមហា ប៉ោង-យុ ...... ៤៨៣

— បញ្ញាសជាតក ភាគទី ៣ (តមក) .... បណ្ឌិតមហា ឈឹម-ស៊ុម .... ៤៩១

*ផ្នែកអក្សរសាស្ត្រ*

— និទានសុភាសិត ............. ព្រះមហា ម៉ៅ-ទាន់ ...... ៥០១

— រឿងសៅរសោយ (តមក) .:...... ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម ... ៥០៦

— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ-កន .......... ៥១៦

— ដំណឹងតាមខ្យល់ក្នុងកន្ទារៈ (តមក) ... លោក ដេង-ជ្រីវ ........ ៥២៦

— រឿងបល្ល័ង្កទិព្យ (តមក) .......... លោក វ៉ាយ-ប៊ុក ........ ៥៣៥

*កំណត់នឹងប្រវត្តិការណ៍*

— ពិធីហែព្រះសារីរិកធាតុនៅព្រៃនគរ .... ព្រះញាណកោសលញាណ-ឈឺន ៥៤៣

— របៀបសិក្សានៃសាលាបាលីជាន់ខ្ពស់ ... ពុទ្ធសាសនបណ្ឌិត្យ ....... ៥៥៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជារ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES


| PARTIE RELIGIEUSE: | | Page |
|---|---|---|
| — Dhammanudhammappatipatti-katha | *Brah Moha* THONG-YU | 483 |
| — Pannasajataka-vol. 3 (suite) | M. CHHIM-SOUM | 491 |
| **PARTIE LITTERAIRE:** | | |
| — Nidanasubhasita | *Brah Moha* MAO-KHANN | 501 |
| — Le « SAU-SOY » ou l'Influence saturnienne (suite) | *Brah Moha* PEUNG-PAM | 506 |
| — Histoire de SAMKOK (suite) | *Oknha* NOU-KAN | 516 |
| — Le souffle du désert (suite) | M. PHENG-CHRIV | 526 |
| — Les trente deux récits du TRONE (suite) | M. RAY-BUC | 535 |
| **NOTES ET CHRONIQUES:** | | |
| — Réception des Reliques Sacrées à Saigon | *Vén.* NHEAN-CHHOEUN | 543 |
| — Programme d'Etudes de l'Ecole Supérieure de pali | *Institut Bouddhique* | 554 |


Prix d'abonnement annuel (comprenant 12 numéros) 210$00

# ផ្នែកសាសនា

ធម្មានុធម្មប្បដិបត្តិកាថា

ព្រះមហាឃោង-យុ វឌ្ឍសារ៉េន

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមេ តមេសទីកោមំ សុរេសោអបនាបសុ

សុបិអធសិតិបុវិ សិវេកុកោកគោទរ ។

ខ្ញុំព្រះករុណា សូមថ្វាយបង្គំចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ ព្រះអង្គ គឺព្រះតណ្ហង្ករ: ព្រះមេធង្ករ: ព្រះសរណង្ករ: ព្រះទីបង្ករ: ព្រះកោណ្ឌញ្ញ: ព្រះមង្គល: ព្រះសុមន: ព្រះរេវត: ព្រះសោភិត: ព្រះអនោមទស្សី ព្រះបទុម: ព្រះនារទ: ព្រះបទុមុត្តរ: ព្រះសុមេធ: ព្រះសុជាត: ព្រះបិយទស្សី ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថ: ព្រះតិស្ស: ព្រះបុស្ស: ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធ: ព្រះកោនាគមន: ព្រះកស្សប: ព្រះគោតមសម្មាសម្ពុទ្ធ ដោយសេចក្ដីគោរព ។

ឯតេន សច្ចវជ្ជេន សុវត្ថិ ហោតុ សព្វទា

ដោយពាក្យសច្ចនេះ សូមសិរីសួស្ដីជោគជ័យមង្គល កើតមានដល់ពពួកពុទ្ធបរិស័ទ គ្រប់ៗ កាលកុំបីឃ្លៀងឃ្លាត ! ។

បន្ទាប់អំពីកិរិយានមស្សការនេះទៅ ខ្ញុំព្រះករុណា អាត្មាភាពនឹងប្រារព្ធសំដែងព្រះសទ្ធម្មឈ្មោះ "ធម្មានុធម្មប្បដិបត្តិ" តទៅ ។ តែមុននឹងលើកយកធម៌នេះមកសំដែង សូមអធិប្បាយសម្រួលសេចក្ដីបន្តិចដូចតទៅនេះ ៖

បណ្ដាមនុស្សសត្វទាំងឡាយដែលកើតមកក្នុងភាជនលោក រមែងមានការប្រព្រឹត្តិផ្សេង ៗ គ្នាគឺ ខ្លះប្រព្រឹត្តតាមធម៌ ខ្លះមិនប្រព្រឹត្តតាមធម៌ ឬខ្លះប្រព្រឹត្តតាមដែរ ប៉ុន្តែនៅស្មោកគំនិត មិនមានសន្ទុះលឿនទៅមុខទៀត ដោយគិតឃើញថា: ការអនុវត្តិតាមសាសនធម៌នេះ តែត្រឹមប៉ុណ្ណោះឯង, គ្មានគុណជាតិអ្វីឲ្យវិសេសលើសជាងការប្រព្រឹត្តិបែបនេះទៅទៀតទេ, អ្នកប្រព្រឹត្តធម៌បែបនេះឈ្មោះថា មិនញុំាងប្រយោជន៍របស់ខ្លួនឲ្យបានល្អតលាស់ជាសាធារណៈទូទៅដល់មនុស្សជាតិគ្រប់គ្នាទេ ។ ជនខ្លះទៀត ប្រព្រឹត្តតាមធម៌ពិត ៗ ទាំងប្រាថ្នាឲ្យកើតប្រយោជន៍ដល់មនុស្សជាតិគ្រប់ប្រាណ បានស្បើយបាកខ្ពុកបំភ្លឺភ្នែកមនុស្សក្នុងលោកឲ្យស្គាល់គុណ, ទោស, ខុស, ត្រូវ, បុណ្យ, បាប, ប្រែក, នរក, ហើយនឹងសេចក្ដីចំរើន-មិនចំរើន តែងចួបប្រទះឃើញផលានិសង្សដែលកើតមកពីការប្រព្រឹត្តិស្មោះត្រង់ ចំពោះធម៌ដែលពិតប្រាកដនោះឬក៏បានបង្ហាញ ពន្យល់គ្នីគ្នាឲ្យចេះដឹង យល់ចូលចិត្ត ស្ដាប់បានថាការប្រព្រឹត្តិបែបនេះ បែបនោះ ជាគុណជាទោស; មិនឲ្យស្ទាក់ស្ទើរទញ្ញុំគុះគំនិតក្នុងការអនុវត្តិទៅតាមធម៌ពិតប្រាកដនោះឡើយ ទាំងដឹងច្បាស់ថា អាត្មាប្រព្រឹត្តតាមធម៌នេះ ឈ្មោះថាប្រព្រឹត្តធម៌ត្រូវ បើ

អាត្មាអញប្រព្រឹត្តត្រូវតាមធម៌ល្អ ដែលអ្នកប្រាជ្ញទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម ធ្លាប់ប្រព្រឹត្តមកនោះ នឹងបានសេចក្ដីសុខប្រាសចាកទុក្ខគ្រប់យ៉ាង ក្នុងជាតិបច្ចុប្បន្ននេះ នឹងបរលោកនាយជាពុំខាន មិនធ្លាក់ទៅសោយទុក្ខឡើយ ។

សមដូចគាថាជាពុទ្ធភាសិតក្នុងធម្មបាលជាតកថា:

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

ប្រែថា "ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តនូវធម៌, ធម៌ដែលបុគ្គលសន្សំទុកល្អហើយ រមែងនាំមកនូវសេចក្ដីសុខ, (ភាពនៃការនាំមកនូវសេចក្ដីសុខ) បែបនេះឯង ជាអានិសង្សក្នុងធម៌ដែលបុគ្គលសន្សំហើយដោយប្រពៃ, បុគ្គលអ្នកប្រព្រឹត្តតាមធម៌ រមែងមិនទៅកាន់ទុគ្គតិឡើយ" ។

ការប្រព្រឹត្តធម៌មួយបែបទៀត ចាត់ជាឧត្តមគតិ តួយ៉ាងដូចជាព្រះបរមគ្រូរបស់យើង ក្នុងពេលដែលកំពុងគ្រប់គ្រងរាជសម្បត្តិនោះ ឈ្មោះថាទ្រង់ប្រព្រឹត្តធម៌ដែរ, ប៉ុន្តែធម៌នោះ នៅប្រឡូកប្រឡំដោយសេចក្ដីសៅហ្មង គឺជារកចរិយារបស់ធម៌ដែលព្រះអង្គប្រព្រឹត្តនោះ ឲ្យមានខ្លឹមសារមានសេពិតប្រាកដពុំបាន រកជាប្រយោជន៍ដល់មនុស្សសត្វទាំងអស់ទៅក្នុងបរលោកនាយគ្មាន, មានប្រយោជន៍តែក្នុងបច្ចុប្បន្នម្យ៉ាង ហើយ

មិនទាំងបានគ្រប់គ្នាផង; ព្រោះហេតុនេះហើយ បានជាទ្រង់ខំលាកលះ
ប្រាណ របស់ព្រះអង្គចេញទៅកសាងមហាភិនិក្ខ្រមណ៍ ទាំងពាក់
កណ្ដាលអធ្រាត្រស្ងាត់មានសេះកណ្ឋកៈជាពាហនៈ មានឆន្នាមាត្យជា
អ្នកកំដរជូនដំណើរព្រះអង្គចេញទៅ ដើម្បីបព្វជ្ជាបួសស្វែងរកធម៌ពិត
ប្រាកដនោះ, លុះស្លៀកដណ្ដប់ត្រៃចីវរជាទង់ជ័យព្រះអរិយៈ នៅត្រើយ
ស្ទឹងអនោមានទីលើផ្ទៃខ្សាច់នោះ ហើយដល់ថ្ងៃទី ៨ ស្ដេចយាងដោយ
ព្រះបាទាឆ្ពោះសំដៅទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត រួចស្ដេចទៅ
គង់ក្នុងញកបណ្ឌវបព៌តធ្វើភត្តកិច្ច រួចបានសន្ទនាជាមួយនឹងព្រះបាទពិម្ពិ-
សារៈម្ចាស់ផែនដីក្រុងរាជគ្រឹះ ។ ព្រះពោធិ៍ទ្រង់បានទទួលអារាធនាថា: បើ
ព្រះអង្គបានត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណវេលាណា សូមមេត្តា
និមន្តមកប្រោសញោមមុនគេកុំខាន ។ ព្រះទសពលញាណទ្រង់ទទួល
ប្ដេជ្ញានោះ ដោយតុណ្ហីភាព ហើយលុះតពីនោះមកទ្រង់បានទៅកាន់
សំណាក់អាឡារៈនឹងឧទកតាបសទាំងពីររូប, ព្រះអង្គបានរៀនយកនូវបរិ-
កម្មការនៃកសិណសមាបត្តិទាំង ៨ តែតាបសទាំងពីររូបនេះមានឈានទៅពាក់
ទើរនៅត្រឹមឋានព្រហ្មលោករកទីបំផុតទុក្ខ ពោលគឺព្រះនិព្វាន ដែល
ពិសេសក្រៃលែងជាងឋានព្រហ្មលោកគ្មាន ដោយយល់ឃើញថា គ្មាន
អ្វីហួសពីព្រហ្មលោកទៅទៀតទេ, ម្ល៉ោះហើយក៏ទញ់កើលគំនិតទើរត្រឹម
នោះឯង ។ ចំណែកព្រះបរមគ្រូរបស់យើង ទ្រង់មិនពេញព្រះទ័យ
ត្រឹមប៉ុណ្ណោះឡើយ ព្រោះទ្រង់យល់ឃើញថា ការប្រព្រឹត្តិរកធម៌ពិត
ប្រាកដនោះមិនមែនអស់ហើយត្រឹមឋានព្រហ្មលោកនេះទេ, គង់នៅមាន

គុណជាតិប្រសើរមួយដែលកើតពីការប្រព្រឹត្តតាមធម៌ពិត ហើយឲ្យសុខជាកំរៃផលកើតចាស់-ឈឺ-ស្លាប់រកទីបំផុតទុក្ខចប់ចុង-ដើមឃើញពុំខានឡើយ, លុះទ្រង់មិនទញ់ព្រះទ័យដូច្នេះហើយ ក៏លាតាបសទាំងពីររូបឆ្ពោះទៅឧរុវេលប្រទេស ខំព្យាយាមប្រព្រឹត្តតាមរកធម៌ពិតអស់ ៦ វស្សា ត្រាតែបានត្រាស់ជាព្រះអរហំសម្មាសម្ពុទ្ធ ប្រាកដឡើងក្នុងលោក ដោយបុណ្យបារមីធម៌ដែលព្រះអង្គសាងសន្សំទុកដោយល្អ រមែងនាំសុខមកប្រគល់ឲ្យចំពោះព្រះអង្គឥតមានល្អៀង ថែមទាំងព្រះអង្គផ្សាយធម៌វិន័យទុកឲ្យយើងប្រតិបត្តិតាមធម៌ពិតនោះ ជាប្រយោជន៍ផ្លូវលោកនិងផ្លូវធម៌កល់គ្នាទៀត ។

ហេតុនេះ យើងជាពុទ្ធបរិស័ទទាំងឡាយគួរតែប្រព្រឹត្តធម៌ឲ្យប្រពៃ ព្រោះការប្រព្រឹត្ត ឬសន្សំធម៌ល្អមកដាក់ខ្លួន ឈ្មោះថាបានដើរទៅតាមផ្លូវមជ្ឈិមាបដិបទា គឺអដ្ឋង្គិកមគ្គ (ផ្លូវមានអង្គ ៨) ជាដំកយដែលបណ្ឌិតទាំងឡាយ មានព្រះសម្ពុទ្ធជាដើមធ្លាប់បានប្រព្រឹត្តតាម ជាផ្លូវញ៉ាំងមារនិងសេនារបស់មារឲ្យវង្វេងក័ន្ទកាំង គួរយើងជាពុទ្ធសាសនិកជន ដើរឲ្យសមតាមពុទ្ធបំណង ដូចមានពុទ្ធភាសិតក្នុងគម្ពីរធម្មបទដ្ឋកថា ត្រង់ធម្មដ្ឋវគ្គថា:

ឯតញ្ហិ តុម្ហេ បដិបជ្ជថ មារសេនប្បមោហនំ
ឯតញ្ហិ តុម្ហេ បដិបន្នា ទុក្ខស្សន្តំ ករិស្សថ

ប្រែថា "អ្នកកល់គ្នា ត្រូវដើរទៅតាមផ្លូវមានអង្គ ៨ នុ៎ះចុះ ជាផ្លូវ

ដែលញ៉ាំងមារនិងសេនារបស់មារឲ្យវង្វេង, ព្រោះថាបើអ្នករាល់គ្នាដើរទៅតាមផ្លូវហ្នឹងហើយ នឹងធ្វើនូវព្រះនិព្វានជាទីបំផុតទុក្ខបាន” ។

អធិប្បាយថា: បណ្ដាផ្លូវទាំងឡាយ ដែលពួកសត្វដើរទៅមកដោយជើង ឬយានជំនិះសព្វថ្ងៃ បើទុកជាផ្លូវនោះស្អាតស្រួល ក៏គង់មានឧបសគ្គន្តរាយទាំងឡាយមានចោរ, បន្លា, គ្រួសជាដើមក៏មាន. ឯផ្លូវដែលព្រះបរមសាស្ដា ទ្រង់ត្រាស់ឲ្យពុទ្ធសាសនិកទាំងឡាយជាបរិស័ទធ្វើដំណើរទៅនោះ ហៅថា មជ្ឈិមាបដិបទា ផ្លូវប្រតិបត្តិយ៉ាងកណ្ដាលមិនតឹងពេកមិនធូរពេក ដូចខ្សែឫស្សីជទ្រីដែលគេរឹតឲ្យល្មម មានសូរស័ព្ទសម្លេងពីរោះ មុខគួរឲ្យជាប់ចិត្តដល់អ្នកស្ដាប់; មិនមែនដូចផ្លូវធម្មតានោះទេ, មជ្ឈិមាបដិបទា ដំណើរផ្លូវនៃសេចក្ដីប្រតិបត្តិយ៉ាងមធ្យមនោះ អាចញ៉ាំងមនុស្សសត្វ-ទេព្ដាក្នុងត្រៃភពឲ្យភ្លឺភ្នែកយល់ច្បាស់ប្រាសចាកអវិជ្ជាសេចក្ដីងងឹតល្ងង់ខ្លៅបាន, ផ្លូវដែលប្រកបដោយអង្គ ៨ នោះគឺ:

១– សម្មាទិដ្ឋិ (សេចក្ដីយល់ត្រូវ), ២– សម្មាសង្កប្ប: (ការត្រិះរិះត្រូវ), ៣– សម្មាវាចា (ពាក្យសំដីត្រឹមត្រូវ), ៤– សម្មាកម្មន្ត: (ការងារត្រឹមត្រូវ), ៥– សម្មាអាជីវ: (ការចិញ្ចឹមជីពជន្មត្រឹមត្រូវ), ៦– សម្មាវាយាម: (ព្យាយាមត្រឹមត្រូវ), ៧– សម្មាសតិ (ការរលឹកឃើញត្រូវ), ៨– សម្មាសមាធិ (ការតាំងចិត្តខ្ជាប់ខ្ជួនត្រូវ) ។

អដ្ឋមគ្គទាំង ៨ នេះ មិនបានអធិប្បាយឲ្យគ្រប់ទាំងអស់ទេ សូមអធិប្បាយតែអង្គទី ១, ទី ៣, និងទី ៨ ។

អង្គទី ១- សម្មាទិដ្ឋិ (សេចក្តីយល់ត្រូវ) ចែកចេញជាពីរប្រការ, ប្រការទី ១ គឺយល់ត្រូវក្នុងផ្លូវលោក, ប្រការទី ២ គឺយល់ត្រូវក្នុងផ្លូវធម៌ ។ ឯការយល់ត្រូវក្នុងផ្លូវលោកនោះ គឺការយល់ថាកើតមកជាពលរដ្ឋក្នុងប្រទេសនីមួយ ៗ ត្រូវគោរពកោតខ្លាចច្បាប់សម្រាប់ផែនដី, យល់ថាគួរតែស្រឡាញ់គ្នាព្រួតកម្លាំងគ្នាកសាងប្រទេសជាតិឲ្យថ្កុំថ្កើងរុងរឿង, យល់ថាគួរតែដឹកចម្លងជាតិដូចគ្នាឲ្យចេះដឹង និងយល់ឃើញថាត្រូវគោរពសាសនា, មហាក្សត្រ ជាប្រមុខរបស់ជាតិឲ្យពេញទី ។ ការយល់ឃើញយ៉ាងនេះ ហៅថាយល់ឃើញត្រូវក្នុងផ្លូវលោក ។ គួរប្រជាជាតិទាំងឡាយ សន្សំការយល់ឃើញបែបនេះ ឲ្យកើតមានក្នុងសន្តានឲ្យបានគ្រប់គ្នាឡើង ។

ឯការយល់ត្រូវក្នុងផ្លូវធម៌នោះ គឺការយល់ថាសត្វដែលកើតមកក្នុងសង្សារវដ្តនេះតែងស្លាប់ទៅវិញ កាលដែលស្លាប់ទៅមានតែបុណ្យបាបទេដែលទៅជាប់ជាមួយនឹងខ្លួន ដូច្នេះ អាត្មាអញមិនត្រូវការប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្តឡើយ ។

អង្គទី ៣- សម្មាវាចា (ពាក្យសំដីត្រឹមត្រូវ) គឺពាក្យសំដីដែលនិយាយត្រឹមត្រូវតាមច្បាប់, មិននិយាយផ្តេសផ្តាសដែលរកគោលរកចារីកគ្មាននោះទេ; មួយវិញទៀត សំដីដែលត្រូវនិយាយទៅរកមនុស្សជាតិដូចគ្នា ត្រូវតែពោលជាសុភាសិតវាចា (ពាក្យជាសុភាសិត) មិនត្រូវពោលជាទុព្ភាសិតវាចា (ពាក្យជាទុព្ភាសិត) ឡើយ, ព្រោះទុព្ភាសិតវាចាមិនហុចផលប្រយោជន៍ដល់អ្នកស្តាប់ឬឲ្យបានចំរើនឲ្យជាតិ

ថ្លៃថ្នូរទេ ។ សុភាសិតាវាចា ទើបបានចំរើនផលដល់អ្នកស្តាប់ បានរស់រានមានជីវិតទៅអនាគត សមដូចពុទ្ធភាសិតថា សច្ចំ វេ អមតា វាចា "ពាក្យពិតជាពាក្យមិនចេះស្លាប់" ។

ហេតុនេះ យើងកើតមកទាន់ពុទ្ធសាសនាគួរពេញចិត្តនាំគ្នានិយាយតែពាក្យណាដែលមានប្រយោជន៍ក្នុងផ្លូវធម៌ ទាំងផ្លូវលោកដើម្បីជាប្រយោជន៍ដល់ជាតិជាមួយគ្នា គឺត្រូវនិយាយឲ្យចំរើនដល់សីលធម៌ទាំងវឌ្ឍនធម៌ក្នុងព្រះនគរតទៅ ។

អង្គទី ៨– សម្មាសមាធិ ការតាំងចិត្តខ្ជាប់ខ្ជួនត្រូវនោះ គឺយើងជាអ្នកកាន់ព្រះពុទ្ធសាសនាទាំងគ្រហស្ថទាំងបព្វជិត គួរតែតាំងចិត្តឲ្យមាំគោរពធម៌ស្រឡាញ់ធម៌ខំបណ្តុះធម៌ ជាពាក្យប្រៀនប្រដៅទាំងផ្លូវលោកផ្លូវធម៌ឲ្យពិតប្រាកដ ពុំគួរធ្វើចិត្តឲ្យឃ្លៀងឃ្លាតចាកការតាំងចិត្តត្រូវនោះឡើយ ព្រោះការតាំងចិត្តត្រូវជាគុណនាំមកនូវប្រយោជន៍សេចក្តីសុខ-ចំរើនក្នុងផ្លូវលោកទាំងផ្លូវធម៌ដោយពិត ។

អយំ ធម្មទេសនា សង្ខេបេន សម្មត្តា

ធម៌ទេសនា ដែលសំដែងមកនេះ សូមសន្មតថាចប់ដោយបំប្រួញតែប៉ុណ្ណោះ ឯវំ ។

# បញ្ញាសជាតក

## ភាគទី ៣

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## សុវណ្ណកុមារជាតក ទី ១៨

លោកអាចារ្យ ឯង-សមិទ្ធ ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

(តមក)

---

ព្រះបាទសុវណ្ណកុមារ ទ្រង់ទតឃើញពួកពលដូច្នោះហើយ ក៏ទ្រង់ព្រះចិន្តាថា "មនុស្សនឹងទេវតាទាំងឡាយ ដែលបានសម្បត្តិនឹងសេចក្តីសុខនឹងឫទ្ធិដ៏ច្រើនយ៉ាងនេះ ប្រាកដជាបានដោយតេជៈបុណ្យ មិនមែនបានដោយតេជៈអ្វីដទៃឡើយ, បើដូច្នោះមានតែអាត្មាអញ ឲ្យពួកពលធ្វើបុណ្យសិនទើបគួរ, ព្រោះបុណ្យរមែងរក្សាបុគ្គលអ្នកធ្វើឲ្យផុតពីសេចក្តីអន្តរាយបាន" លុះទ្រង់ព្រះចិន្តាដូច្នោះហើយ ទើបទ្រង់ឲ្យធ្វើចង្ហាន់បិណ្ឌបាតបវរដ៏ថ្លៃថ្លា ព្រមទាំងគ្រឿងសេនាសនៈឲ្យនិមន្តព្រះភិក្ខុសង្ឃមកប្រគេនទេយ្យទាននោះហើយ ឲ្យសាងកំលុកចេតិយ, ព្រះបក្រីទ្រង់ព្រះចិន្តាថា "បើដំណើររបស់អាត្មាបានសម្រេចដូចប្រាថ្នា ក៏ជាការស្រួលល្អ, បើពុំបានសម្រេចទេ ក៏អាត្មាអញគង់បានសម្បត្តិ ៣ ប្រការក្នុង

កពទាំងពួងដែរ" ហើយទ្រង់ក៏យកព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹងទីរលឹក សមាទានសីលស្តាប់ធម៌ទេសនា រៀបគ្រឿងក្រយាបូជា ឲ្យទានឃ្លាយទឹកទំបំណាក់សំពត់អាវស្បៃទីងរថដ៏រទេះសាជាដើម ហើយទ្រង់ស្រូចទឹកស្រោចឧទកអធិដ្ឋានថា ពួកសត្វទាំងឡាយ មានញាតិសន្តានជាដើមដរាបដល់សត្វក្នុងអវិចីនរក សូមឲ្យរួចផុតបាកទុក្ខទោសទាំងពួង, ឲ្យបានសុខគ្រប់ប្រការក្នុងភពទាំង ៣, ទាំងពួកពលសេនីយ៍សេនាបតីនាម៉ឺនសព្វមុខមន្ត្រីទាំងអស់ ក៏សូមឲ្យបានសេចក្តីសុខរួចបាកទុក្ខទាំងពួងជាដរាបតរៀងទៅ ដោយតេជះនៃសេចក្តីអធិដ្ឋាននោះ ក៏ពួកសត្វក្នុងអបាយទាំងឡាយ បានរួចបាកទុក្ខហើយសោយសម្បត្តិជាសុខក្នុងពិភពតាវត្តិង្សមានពួកទេពអប្សរជាច្រើនកោដិហោមរោមជាបរិវារ; ញាតិឯណាដែលបានកើតក្នុងទេវលោកស្រាប់ហើយ ក៏រឹតតែបានសោយសេចក្តីសុខជាតិយោភាព ក្រៃលែងជាងដើមតទៅ ។

ព្រះបាទសុវណ្ណកុមារ ទ្រង់ស្តេចទៅដល់ត្រើយសមុទ្ទ ជាមួយនឹងពួកពលសកលយោធា លុះវេលាពាក់កណ្តាលរាត្រី ទើបព្រះឧរបតីទ្រង់ព្រះចិន្តាថា ស្តេចគជេសុរពជ មានអានុភាពអំណាចយ៉ាងណាទៅអេះ? ។ លុះទ្រង់កំពុងមានព្រះតម្រិះដូច្នេះ ក៏ពិភពសម្តេចព្រះឥន្ទ្រាធិរាជបញ្ចេញចំណាការរក្តៅខុសប្រក្រតី ដោយតេជានុភាព នៃព្រះបាទសុវណ្ណកុមារពោធិសត្វនោះ ។ លុះសក្កទេវរាជទ្រង់អាវជ្ជនាការពិចារណាគ្រប់ហេតុនោះសព្វគ្រប់ហើយ ពុំយូរឡើយក៏ទ្រង់ចុះមកកាន់សំណាក់ព្រះសុវណ្ណកុមារ ព្រះហត្ថាកាន់ធ្នូព្រះឥន្ទ្រ ព្រមទាំងកូនសរ ៥ ផង

មកហៅព្រះសុវណ្ណកុមារថា ហៃមហាបុរស, ចូរអ្នកក្រោកឡើង, យើងនឹងឲ្យអាវុធមុះមុតចំឡែក ដែលអាចញាំញីនូវសត្រូវបច្ចាមិត្រទាំងពួងបាន; សរទាំង ៥ នេះ សរ ១ បាញ់បានចម្ងាយ ១ យោជន៍អាចកាត់ក្បាលមនុស្សទៅតាទាំងពួងបាន, សរ ១ ទៀត អាចនិម្មិតជាយានជំនិះបាន, សរ ១ ទៀត អាចនិម្មិតជាវិមានផុះលើអាកាស, សរ ១ ទៀត កើតជាភ្លក់ភ្លើង, សរ ១ ទៀត អាចមុតមនុស្សសត្វដល់ទៅគ្រប់ ៧ ថ្ងៃទើបស្លាប់ ។

ព្រោះហេតុនោះបានជា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា សរ ១ អាចកាត់ក្បាលពួកជនបាន, សរ១ និម្មិតជាយានជំនិះ, សរ១ និម្មិតជាវិមាន សរ ១ កើតជាភ្លក់ភ្លើង, សរ ១ អាចមុតអស់ ៧ ថ្ងៃ ទើបប្រល័យជីវិតឲ្យស្លាប់ ។

ព្រះឥន្ទ្រាធិរាជត្រាស់ថា យើងឲ្យគន្ធព្វ ព្រមទាំងកូនសរ ៥ ដល់ព្រះអង្គ ចូរព្រះអង្គទទួលយកចុះ ។ ព្រះពោធិសត្វក៏ទទួលយកដោយសេចក្ដីត្រេកអរសោមនស្សចំពោះអាវុធនោះក្រៃពេក ។ លុះសក្កទេវរាជប្រទានអាវុធនោះស្រេចហើយ ទើបស្ដេចទ្រង់ត្រាស់ជាគាថាថា

ជយេហិ ត្វំ មហារាជ សព្វង្គនេសុ បាកដោ
បត្ថេសុ មនុស្សា តុយ្ហំ អាណា ភវន្តុ តេ

បពិត្រមហារាជ, សូមព្រះអង្គទ្រង់មានជ័យជំនះឈ្នះអស់សត្រូវ, សូមឲ្យព្រះរាជតេជះរបស់ព្រះអង្គប្រាកដទៅសព្វទិសទី លើបណ្ដាជនជាតិជាមនុស្សក្នុងទ្វីបទាំងបួន, សូមឲ្យព្រះរាជអាជ្ញារបស់ព្រះអង្គមានសព្វៗកាល ។

សក្កទេវរាជ ទ្រង់ប្រទានពរស័ព្ទសាធុការហើយ ក៏ត្រឡប់ទៅកាន់ឋានរបស់ព្រះអង្គវិញ ។ គ្រានោះ ព្រះមហាសត្វទ្រង់ត្រួតពួកពលដែលប្រជុំគ្នាជាពួកជាកង ឃើញមានរបៀបរៀបរយស្រួលល្អ ហើយទើបទ្រង់នាំចុះកាន់សំពៅទៅវេលាប្រកបដោយនក្ខត្តឫក្សល្អ បើកលឿនស្លៅទៅកង់សមុទ្ទជលសា ។ គ្រានោះ ពួកសមុទ្ទទេវតា ក៏នាំគ្នាហោះឆ្ពោះនាំផ្លូវព្រះពោធិសត្វ ខ្លះចាក់ស្បៀងលៀងពួកពលសកលយោធា, ខ្លះចូលអង្គុយត្រៀបត្រា គាល់ព្រះពោធិសត្វដោយសេចក្ដីគោរព ។ ពួកពលទាំងឡាយប្រកបដោយសេចក្ដីសុខសប្បាយគ្មានអន្តរាយអ្វីឡើយ ។ កាលព្រះបរមបពិត្រទ្រង់បានដល់ត្រើយខាងនាយហើយ ក៏បោះកងទ័ពសំចតនៅកងទ័ពនោះទ្រង់បញ្ជូនរាជទូតឲ្យទៅទូលព្រះបាទកដេសុរាជ ។ រាជទូតនោះទៅដល់ហើយ ក៏ក្រាបទូលព្រះបាទកដេសុរាជថា បពិត្រព្រះរាជសម្ភារ, ព្រះបាទសុវណ្ណកុមារម្ចាស់យើង ជាព្រះរាជបុត្ររបស់ព្រះរាជាធិរាជ ទ្រង់ជាមហាវីរបុរស មានអំណាចអាចញាំញីពួកស្ដេចជាសត្រូវបច្ចាមិត្របានឥតមានញញើតត្រឹមតែសរ ១ របស់ព្រះអង្គ ក៏អាចកំទេចនគរនឹងខែត្រដែននេះបានដែរ, ឥឡូវនេះទ្រង់ស្ដេចមកដល់ ជាមួយនឹងពួកពលសកលយោធា, បើដូច្នោះ សូមព្រះអង្គស្ដេចទៅមីមា ទៅអង្វរករទៀបព្រះបាទា សូមអាយុជីវិត, ឬមួយបើព្រះអង្គអាងមហិទ្ធិឫទ្ធិ ក៏សូមព្រះអង្គទ្រង់គិតរៀបចំគ្រឿងចម្បាំង ចេញទៅតតាំងច្បាំងគ្នាចុះ ។ ចំណែកខាងព្រះបរមពោធិសត្វ ក៏ថ្លែងសរ ១ ប្រើទៅជាអាវុធទូតទៀត

បង្គាប់សេះនោះថា ម្នាលសេះដ៏ចំរើន, ចូរឯងទៅបិតនៅក្បែរគុម្ពត្របៀក ស្តេចកេសររាជហើយប្រាប់ថា នែស្តេចកំណាច, បើប្រស្តេចមិនរក់សេះវៃទៅថ្វាយបង្គំព្រះបាទព្រះម្ចាស់យើងទេ, យើងនឹងកាត់ក្បាលប្រស្តេចឯងយកទៅថ្វាយព្រះម្ចាស់យើងមិនខាន ។ សេះនោះក៏ធ្វើតាមព្រះរាជបញ្ជា ។ ព្រះបាទកេសររាជនោះ លុះឮដូច្នោះហើយ ក៏ក្រេវក្រោធពិរោធមហិមា ដូចជានាគរាជដែលគេប្រហារកន្ទុយដោយដំបងដែក មានសេចក្តីភិតភ័យក្រៃពេក, ប៉ុន្តែទំធ្វើកិរិយាកំឡាក្រវីក្រពាមានព្រះដំកស់ត្រាស់ហៅពួកអាមាត្យដែលក្លាហានសំខាន់ៗមកប្រជុំប្រឹក្សាណែនណាន់ពេញក្នុងទីព្រះលានហើយត្រាស់ថា អាដែងសុវណ្ណកុមារ ជាអ្នកប៉ិនប្រសប់ដោយសិល្បឥទ្ធិ ជាមនុស្ស ១ មានអានុភាពច្រើន, ប៉ុន្តែថ្វីបើដល់ម្ល៉ោះ ក៏យើងនៅតែមិនខាញ់វា ។ ពួកអ្នកនគរទាំងអស់ ក៏ជ្រួលជ្រើមភ្ញាក់ផ្អើលតែកល់ៗគ្នា ។ កូនសេះដែលជារាជទូត ក៏ត្រឡប់មកទូលព្រះពោធិសត្វតាមពាក្យដែលខ្លួននិយាយ ។ ទើបព្រះពោធិសត្វ ទ្រង់ថ្វីសេះ ១ ទៀត ដែលអាចកាត់សក់ជនានុជន ។ សេះនោះក៏ស្ទុះទៅកាត់សក់អ្នកនគរ ធ្វើឲ្យត្រដាលត្រដិលវិលអាក្រក់ទាំងអស់គ្នា ហើយម្នីម្នារិលមកចូលក្នុងបំពង់របស់ខ្លួនវិញ ។ ពួកក្នុងព្រះបរមរាជវាំងក៏អ្នកនគរទាំងអស់ក្តី ក៏ជាទុក្ខម្នេញ កើតមានសេចក្តីអៀនខ្មាស ដើរក៏មិនស្រណុក អង្គុយក៏មិនសុខ មើលតែមុខគ្នាព្រួយចិត្ត ។ លំដាប់នោះ មហាបុរស ទ្រង់ថ្វីសេះ ១ ទៅទៀត ។ សេះនោះក៏កើតជាយាន មានសេះ មានរាជរថសុទ្ធសឹងតែថ្មីៗ មានគ្រឿងរចាំត្បូងត្រ

មានស្រីអប្សរអគ្គិយកន្ទករជរថនោះ, ហិចហោះទៅប្រទក្សិណខាងក្រៅនគរបីជុំ ៗ ពួកអ្នកនគរទាំងតូចទាំងធំ ព្រមទាំងព្រះរាជាមានសេចក្តីភិតភ័យតក្កមា អគ្គិយទុបហត្ថាសម្ពុំស្ញៀម ៗ លំដាប់នោះ ព្រះមហាបុរស ទ្រង់ថ្វែងសរ ១ ទៀត ដែលអាចបង្កើតជាភ្លើង គ្រាន់តែបើតផ្គងឡើងក៏ពុស្សូរសន្ធឹកដូចរន្ទះអសនី ៗ កូនសរនោះក៏ស្ទុះច្រៀវព្រែបពេញស្មើកើតជាអណ្តាតភ្លើង ឆេះឡើងសន្ធោសន្ធៅ សំដៅទៅក្រឡឹងខាងក្រៅនគរ ៣ ជុំ ហើយចូលទៅក្នុងបំពង់ព្រួញរបស់ខ្លួនវិញ ៗ ឯពួកអ្នកស្រុកអ្នកនគរទាំងអស់គ្នា លុះឃើញហេតុអស្ចារ្យមិនធ្លាប់មានដូច្នោះ ក៏ភិតភ័យមហិមា ស្ទុះស្ទុញបកូនទុបប្រពន្ធទន់ជង្គង់ដេកដួលយំខ្សឹកខ្សួលតែរៀងខ្លួន ៗ ឯព្រះបាទសីហឡរាជទ្រង់មានព្រះជាតិជាអ្នករបឹងរឹងរូស ធ្លាប់មានព្រះរាជហឫទ័យក្លៀវក្លា ទោះបីភិតភ័យយ៉ាងណា ក៏ខំថ្វែងព្រះរាជឧត្ការថា នេះជាអានុភាពរបស់សុវណ្ណកុមារនោះ, ប៉ុន្តែទុកជាដល់ម្ល៉ោះ ក៏គង់តែអញមិនទាន់ចាញ់ ៗ

ឯព្រះមហាបុរស ទ្រង់មិនប្រទុស្តសោះ ព្រោះព្រះអង្គមានព្រះរាជហឫទ័យអាណិតអាសូរករុណា ទ្រង់ ឃើញចំនងគួរនឹងចាប់ព្រះរាជានោះបាន ហើយជ្រាបដោយព្រះប្រាជ្ញាញាណថាមានសេនាបតីចម្បង ២ នាក់ត្រូវស្លាប់ក្នុងរវាង ៧ ថ្ងៃទើបក្សត្រថ្ងៃទ្រង់បញ្ជូនរាជទូតទៅទៀត ៗ រាជទូតនោះ ទៅក្រាបបង្គំទូលព្រះបាទសីហឡរាជថា "វេលារសៀលថ្ងៃនេះ ព្រះបាទសុវណ្ណកុមារនឹងថ្វែងសរឲ្យត្រូវចំនគរនេះពុំខាន ៗ ព្រះបាទសីហឡរាជ ទ្រង់បានត្រាស់បង្គាប់ឲ្យពួកសេវកាមាត្យ រៀបចំ

ពាក់គ្រឿងក្រោះទាំងអស់គ្នា ៗ ក្នុងព្រះនគរក៏កើតកោលាហលដែលច្របល់ជាមួយគ្នា ឥតនរណានៅស្ងៀមបាន ៗ

លំដាប់ពីនោះមក ព្រះបាទសុវណ្ណកុមារ ទ្រង់បញ្ជូនទូត ១ ទៅទៀត ៗ ទូតនោះទៅក្រាបបង្គំទូលព្រះរាជាសីហឡៈថា បពិត្រព្រះរាជសម្ភារ, បើទ្រង់នៅស្រឡាញ់សរីរាង្គកាយរបស់ព្រះអង្គនៅឡើយទេ សូមទ្រង់កុំច្បាំងជាមួយនឹងយើងឡើយ; បើទ្រង់ពុំជឿសោត, សូមទ្រង់ចាំទតចុះ, សាមុខជានឹងមុតអន្តសេនាបតីទាំងពីរនាក់ពុំខាន; បើទុកជាចងគ្រឿងក្រោះយ៉ាងណា, ក៏គង់តែស្លាប់ក្នុងរវាង ៧ ថ្ងៃជាប្រាកដ ៗ គ្រានោះ ព្រះបាទសីហឡៈ ទ្រង់ចង់ជ្រាបហេតុនោះ ទើបទ្រង់ឲ្យចងគ្រឿងក្រោះ រុំស្បែក រុំសំពត់ ព័ទ្ធសរីរសេនាបតីទាំង ២ នាក់ ហើយទ្រង់ឲ្យអង្គុយក្នុងផ្ទះបិទជុំធ្វើដោយក្ដារក្រាស់ៗ ប្រាំពីរស្រទាប់ ៗ ព្រះពោធិសត្វ ទ្រង់ថ្ងៃសរ ១ ទៀតដែលអាចពុះហ្វាទ័យបាន, បណ្ដាំសរនោះថា នែបរជើងរើន, អ្នកចូរទៅចាក់ហ្វាទ័យសេនាបតីទាំង ២ នាក់ ដែលចងគ្រឿងក្រោះអង្គុយក្នុងព្រះរាជមន្ទីរ តាមសេចក្ដីអាចរបស់អ្នកចុះ ៗ សរនោះក៏សុះទៅក្រឡឹងព្រះរាជពិភព ៣ ជុំ បន្ទរឡើងឮស្លូវសំពួសទឹកដូចជារន្ទះអស្សនី ៗ អ្នកនគរកើតភិតភ័យ ខ្លះបានល្អើ ខ្លះបានបង្អើរ មកក្របក្បាល រត់ទៅពួនសម្ងំនៅដោយទីកៀនកោះ ៗ សរនោះ ក៏មុតទម្លាយធ្លាយក្ដារប្រហារដល់ដួងហ្វាទ័យនៃសេនាបតីទាំង ២ នាក់នោះ ដួលដេកស្លាប់ក្នុងព្រះរាជមន្ទីរ ៗ ព្រះរាជាសីហឡៈ បានឃើញហេតុអស្ចារ្យដូច្នោះ ក៏មានព្រះរាជហ្វាទ័យភិតភ័យតក់ស្លុតរន្ធត់

ខ្ពាំង ទើបទ្រង់ត្រាស់ចំពោះអាមាត្យទាំងឡាយថា បើយើងមិនចេញទៅសូមជីវិតទេ, មុខជាបណ្ដាស្រ្តីនឹងយើងទាំងអស់គ្នា ស្លាប់វិនាសអសារឥតការមិនខាន: បើដូច្នោះ គួរតែយើងប្រគល់នគរព្រមទាំងដែនឲ្យគេ សូមរស់តែជីវិតប៉ុណ្ណោះក៏គង់ដូនជាបាន ។ អាមាត្យទាំងប៉ុន្មានក៏ព្រមព្រៀងគ្នាក្រាបបង្គំទូលតបព្រះរាជឱង្ការថា "ឧបាយដែលព្រះអង្គទ្រង់ត្រាស់មកនេះ គួរមែនហើយ" ។ ទើបព្រះរាជាទ្រង់យកមាសប្រាក់កែវកងកៃពទូរ្យសូរ្យកាណវត្ថុផង ជាច្រើនប្រការក្យត្រាទ្រង់ស្ដេចចេញទៅជាមួយនឹងអាមាត្យទាំងឡាយ ចូលទៅគាល់ព្រះបាទសុវណ្ណ-កុមារ លើកគ្រឿងសក្ការបណ្ណាការទាំងអស់ថ្វាយ, ឱនកាយក្រាបលើផែនដី ព្រះបក្រីទ្រង់ត្រាស់ថា

ន នោ ទិដ្ឋោ ឥតោ បុព្វេ ន សុតោបិ ន កស្សចិ
ឯវំ តេជោ មហាបុញ្ញោ តាទិសោ ប មហីតលេ ។
នគរំ រដ្ឋញ្ច[១] សកលំ បាណញ្ច តម្ហាកញ្ចេវ
ទទាមិ តេ មហារាជ យាចាមិ ជីវិតំ តុវត្តិ ។

បពិត្រព្រះអង្គជាឥស្សរាធិបតី, ព្រះបរមសិរីតេជានុភាព នឹងបុញ្ញាភិនិហារខ្លាំងអស្ចារ្យដល់ម៉្លេះ, លើផែនដីនេះខ្ញុំព្រះអង្គពុំដែលឃើញ ពុំដែលឮទេ តាំងតែពីកាលណាមុនៗដរាបមកដល់ថ្ងៃនេះ ។ ខ្ញុំព្រះអង្គសូមថ្វាយនគរនឹងខេត្តដែន

---

[១] នគរំ រដ្ឋញ្ចាតិបិ បាឋោ ។

ព្រមទាំងបណ្ដាប្រជាជនសត្វទិករ ចំពោះព្រះអង្គទាំងអស់ សូមរស់តែជីវិត ។

ព្រះបរមពោធិសត្វ ទ្រង់ត្រាស់ប្រកែកថា បពិត្រព្រះម្ចាស់ផែនដី, ទីក្រុងព្រះនគរវេឡុពជបុរី សូមឲ្យគង់នៅជារបស់ព្រះអង្គដដែលចុះ, សូមទ្រង់កុំភ័យ, សូមទ្រង់មានសេចក្ដីសុខសម្រាន្តកំសាន្តព្រះរាជហឫទ័យឲ្យស្រួលចុះ ខ្ញុំមិនមានគំហើងចង់គ្រងទីព្រះអង្គទេ, ខ្ញុំមិនមកដណ្ដើមយករាជសម្បត្តិ ទីដែនរបស់ព្រះអង្គទេ, ខ្ញុំប្រាថ្នានឹងចាប់យកត្រឹមតែដួងហឫទ័យរបស់ព្រះអង្គប៉ុណ្ណោះទេតើ ។

ព្រះបាទកវេសុរៈ ព្រះចៅផែនសីហឡ: ទ្រង់ព្រះសវនាការព្រះរាជឱង្ការនោះហើយទ្រង់ញាប់ញ័រអស់ព្រះអង្គារយវៈតក់ស្លុតភិតភ័យមានព្រះសោទោហូរចេញសស្រាក់ ។ ព្រះពោធិសត្វទ្រង់ទស្សនាការឃើញព្រះរាជាសីហឡៈកំពុងមានសេចក្ដីញ័រញាក់ ក៏ទ្រង់មានព្រះរាជហឫទ័យករុណា ទើបមានព្រះរាជឱង្ការថា បពិត្រមហារាជ, សូមព្រះអង្គកុំខ្លាច, កុំញាប់ញ័រ, សូមដំកល់ព្រះអង្គឲ្យសុខសំរាន្តកំសាន្តព្រះរាជហឫទ័យឲ្យស្រួលចុះ, បពិត្រព្រះបមជន, ខ្ញុំត្រូវការតែដួងហឫទ័យរបស់ព្រះអង្គ មិនមែនត្រូវការរបស់អ្វីដទៃសម្បូបទ្ទិបបទ្ទូបទេ; បពិត្រព្រះបាទកវេសុរៈ, សូមព្រះអង្គទ្រង់ជ្រាបថា ការចាប់យកដួងហឫទ័យនោះ មិនមែនជាការពុះវះយកដុំសាច់បេះដូងរបស់ព្រះអង្គទេ, គឺសូមឲ្យតែព្រះអង្គមានសេចក្ដីស្រឡាញ់ចំពោះខ្ញុំ, សូមឲ្យខ្ញុំមានសេចក្ដីមេត្រីរាប់អានចំពោះព្រះអង្គបានសព្វកាលទៅផងប៉ុណ្ណោះ; បពិត្រមហារាជ,

ធម្មតាការកាន់យកនូវដួងហឫទ័យនៃជនដទៃ ជាកិច្ចដែលអ្នកផងធ្វើបាន ដោយកម្រណាស់; បានជាជាដូច្នោះ ព្រោះបុគ្គលដែលអនុគ្រោះដល់ជនដទៃ គោងកំណត់ចាប់ដួងហឫទ័យឲ្យបានជាមុនទើបនឹងអាចឲ្យជនដទៃនោះ ប្រព្រឹត្តនូវអំពើដែលជាប្រយោជន៍បាន ព្រមទាំងហាមប្រាមជនដទៃនោះឲ្យវៀរចាកអំពើអាក្រក់ក៏បានទៀត; បុគ្គលអ្នកអនុគ្រោះនោះ ឈ្មោះថាមហាមិត្រ, ទុកជាកែវចិន្តាមណី ក៏មិនស្មើនឹងមហាមិត្រនោះដែរ, ព្រោះហេតុនោះ បានជាអ្នកប្រាជ្ញទាំងឡាយសំដែងថា

ចិន្តាមណី សព្វមណីវិសេដ្ឋោ មណីចិន្តា ឆាម ឆាបិ សមេតិ
ចិន្តាមណី ចិន្តិតមេវ ទត្វា គោ ចិន្តិតាយ ហិតមេវ មិត្តោ។

កែវចិន្តាមណី ប្រសើរវិសេសជាងកែវទាំងអស់, ប៉ុន្តែកែវចិន្តាមណី ក៏មិនស្មើនឹងមហាមិត្រ, ព្រោះ កែវចិន្តាមណីឲ្យសម្រេចប្រយោជន៍ តាមចិត្តគិតត្រឹមតែក្នុងបច្ចុប្បន្នជាតិនេះប៉ុណ្ណោះ នឹងឲ្យសម្រេចរហូតដល់អនាគតជាតិផងពុំបានឡើយ; ឯមហាមិត្រ ទើបឲ្យសម្រេចប្រយោជន៍តាមចិត្តគិតបានសព្វកាល; បុគ្គលឯណា តាំងនៅក្នុងមិត្តធម៌ គឺស្តាប់បង្គាប់យកដម្រាប់តាមពាក្យកល្យាណមិត្រ, បុគ្គលនោះរមែងជាឥស្សរៈក្នុងលោកនេះផង រមែងបាននូវមហាសម្បត្តិក្នុងលោកខាងមុខផង ។ មួយយ៉ាងទៀត បុគ្គលដែលឋិតនៅក្នុងមិត្តធម៌រមែងបានទទួលសេចក្តីសរសើរក្នុងបច្ចុប្បន្នភពនេះផង បាននូវសុគតិក្នុងសម្បរាយភពផង ។ (មា,ឧត)

# ផ្នែកអក្សរសាស្ត្រ

## និទានសុភាសិត

### ព្រះមហាឧត្តមវិជ្ជា ម៉ៅ-ខាង

*រៀបរៀង*

---

"អ្នកប្រាជ្ញយល់ការណ៍ រមែងតាំងខ្លួនបានដោយទ្រព្យជាដើមទុនសូម្បីតិចតួច ដូចគេបង្កាត់ភ្លើងដែលតូច ដូច្នោះ" ។

សេចក្ដីគិតតាំងខ្លួន គឺធ្វើខ្លួនឲ្យមានឡាក់ហានល្មមជាទីពឹងពំនាក់របស់ខ្លួនឯង ឬរបស់អ្នកដទៃបានផងនោះ ជាសេចក្ដីគិតដ៏ល្អ ហើយដែលតែងមានដូចគ្នាគ្រប់ ៗ រូប វៀរលែងតែមនុស្សខ្លះ ដែលធ្លាប់តែពឹងអ្នកដទៃរហូត មិនមានគំនិតគិតទីពឹងខ្លួនឯងនោះ ហើយដែលខាងក្រោយមក ច្រើនតែមានគតិតែម្យ៉ាងដូចគ្នាដោយច្រើន គឺជាមនុស្សអនាថា មិនមានទីពឹង ឬនកាលក្លាយទៅជាមនុស្សពាលខូចកាចប្រព្រឹត្តអាក្រក់ ផ្ដេសផ្ដាសក៏សឹងមាន ។

ក៏ឯអង្គដែលជាហេតុឲ្យតាំងខ្លួនបាននោះ ពោលដោយខ្លីមាន ២ គឺ ភាពជាអ្នកឈ្លាសវាងវៃ មានសេចក្ដីអង់អាចចេះប្រកបការងារឲ្យសមគួរដល់ឱកាសនិងកាលសម័យ១ ទ្រព្យដើមទុន១ ។ បណ្ដាហេតុ២ប្រការនេះ ប្រការខាងដើម ចាត់ជាអង្គគុណដ៏សំខាន់ក្រៃលែង ព្រោះមានតួយ៉ាងជាក់ស្ដែងថា មនុស្សអ្នកឈ្លាសវាងវៃល្អសូម្បីមានទ្រព្យជាដើមទុនត្រឹម

កាកណិកមួយ ដែលមានតម្លៃតិចជាទីបំផុត ប្រហែលនឹងសេន១ប៉ុណ្ណោះ
ក៏អាចកសាងខ្លួនរហូតទៅជាសេដ្ឋីបានមានរឿងតំណាលដូចតទៅនេះ ៖

ក្នុងក្រុងពារាណសី រាជធានីនៃដែនកាសី មានសេដ្ឋីម្នាក់ ឈ្មោះ
ចូឡកសេដ្ឋីជាអ្នកឈ្លាសវៃចេះដឹងសារពើនិមិត្ត ថ្ងៃមួយត្រឡប់អំពីគំនាល់
ព្រះរាជាមក ឃើញកណ្ដុរងាប់មួយនៅផ្លូវថ្នល់ ពិនិត្យមើលឫក្សពារក្នុង
ខណៈនោះ ហើយពោលឡើងថា "កុលបុត្រអ្នកមានចក្ខុ អាចនឹងកាន់
យកកណ្ដុរនេះទៅធ្វើជាដើមទុន មានភរិយានឹងប្រកបការងារបាន" ។
កុលបុត្រកំសត់ម្នាក់ ហៅ "ចូឡកន្តេវាសិក" ជាអ្នកបំរើរបស់សេដ្ឋី បាន
ឮពាក្យរបស់សេដ្ឋីនោះហើយ គិតថា "បើលោកមិនដឹង លោកនឹងមិន
ពោល" ក៏កាន់យកកណ្ដុរនោះទៅ លក់ឲ្យដល់អ្នកចិញ្ចឹមឆ្មាម្នាក់នៅ
រានផ្សារមួយកន្លែង បានទ្រព្យមួយកាកណិករួចយកកាកណិកនោះ ទៅ
ទិញស្ករនឹងទឹកផឹកមួយក្អម ឃើញពួកមាលាការត្រឡប់មកពីព្រៃ ក៏
ឲ្យស្ករមួយដុំៗ ម្នាក់ ហើយឲ្យទឹកផឹកមួយបោយៗ នាយមាលាការបាន
ឲ្យផ្កាដល់គេម្នាក់មួយក្ដាប់ៗ ដោយតម្លៃផ្កានោះ ស្អែកឡើង គេទិញស្ករ
ហើយនឹងទឹកមួយក្អមយកទៅដល់សួនផ្កាតែម្ដង, ថ្ងៃនោះពួកមាលាការ
បានរំលែកផ្កាកន្លះៗ បាច់ឲ្យដល់គេ ។ ដោយឧបាយនេះ មិនជាយូរ
ប៉ុន្មាន គេរកទ្រព្យបាន ៨ កហាបណៈ ។

ថ្ងៃមួយ មានភ្លៀងខ្យល់ កំណាត់ឈើមែកឈើនឹងស្លឹកឈើ ត្រូវ
ខ្យល់បោកបំបាក់ធ្លាក់ក្នុងសួនព្រះរាជា អ្នកថែទាំសួន គិតរកឧបាយនឹង
ជញ្ជូនយកទៅចោលមិនទាន់ ចូឡកន្តេវាសិកទៅដល់ទីសួននោះនិយាយ

នឹងអ្នករក្សាសួនថា "បើលោកឲ្យមែកឈើនឹងស្លឹកឈើទាំងអស់នេះដល់ខ្ញុំ ខ្ញុំនឹងជួយជញ្ជូនចេញឲ្យអស់" អ្នកថែសួនក៏ទទួលថា "យកទៅចុះទៅ" គេទៅកាន់ពួកក្មេងដែលកំពុងលេង ចែកស្ករហើយសុំឲ្យជួយជញ្ជូនមែកឈើនិងស្លឹកឈើចេញ បានអស់ដោយមួយរំពេច ឲ្យគេទុកក្បែរទ្វារសួន ៗ ពេលនោះ ស្នងឆ្នាំងព្រះរាជា ត្រាច់ដើររកឧសដើម្បីដុតភាជនៈដីរបស់ស្ដេច ឃើញគំនរមែកឈើនោះ ក៏សុំទិញអំពីគេ ៗ ថ្ងៃនោះចូឡកន្តេវាសិកលក់ឧសបានទ្រព្យ ១៦ កហាបណៈ រួមទាំងភាជនៈផ្សេងៗ មានពាងទឹកជាដើមទៀត ៥ មុខ ៗ កាលមានទ្រព្យ ២៤ កហាបណៈហើយគេក៏រិះរកផ្លូវដើម្បីធ្វើឲ្យកើតផលតទៅ ក៏បានតាំងពាងទឹកផឹកមួយពាងក្នុងទីមិនឆ្ងាយអំពីទ្វារក្រុង បំរុងបំរើអ្នកច្រូតស្មៅ ៥០០ នាក់ដោយទឹកផឹក ៗ អ្នកច្រូតស្មៅទាំងអស់នោះពោលនឹងគេថា "នែសំឡាញ់! អ្នកមានឧបការៈដល់យើងច្រើន យើងនឹងធ្វើអ្វីដល់អ្នកបានខ្លះ?" ៗ គេតបថា "កាលណាកិច្ចរបស់ខ្ញុំកើតឡើងសឹមធ្វើ" ៗ គេត្រាច់ដើរទៅមកៗ បានធ្វើសេចក្ដីស្និទ្ធស្នាលជាមួយនឹងអ្នកប្រកបការដើរទាំងចំណែកផ្លូវគោក នឹងចំណែកផ្លូវទឹក ៗ អ្នកប្រកបការដើរផ្លូវគោកបានប្រាប់ដល់គេថា "ស្អែកនេះ ឈ្មួញសេះនឹងនាំសេះ ៥០០ មកដល់ព្រះនគរនេះ ៗ គេឮដំណឹងនោះហើយ ទៅរកអ្នកច្រូតស្មៅ ពោលថា "ស្អែកនេះ ពួកលោកឲ្យស្មៅដល់ខ្ញុំម្នាក់មួយបាច់ចុះ នឹង កាលបើខ្ញុំមិនទាន់បានលក់ស្មៅទេ សុំពួកលោកកុំអាលលក់ស្មៅរបស់ខ្លួន" អ្នកច្រូតស្មៅទាំងនោះក៏ទទួលពាក្យ ហើយច្រូតស្មៅ ៥០០ បាច់ មកបោះទុក

ត្រង់ទ្វារផ្ទះរបស់ចូឡកន្តេវាសិក ។ ឈ្មួញសេះត្រាប់ដើរទៅពេញក្រុង មិនបានអាហារសំរាប់សេះ ទើបឲ្យទ្រព្យដល់ចូឡកន្តេវាសិក មួយពាន់កហាបណៈទទួលយកស្មៅ ៥០០ បាច់នោះទៅ ។ តពីថ្ងៃនោះមក មិនបានប៉ុន្មានថ្ងៃសំឡាញ់អ្នកប្រកបការងារផ្លូវទឹក បានប្រាប់ដល់ចូឡកន្តេវាសិកថា "សំពៅធំមកដល់កំពង់ហើយ" ។ ចូឡកន្តេវាសិកប្រញាប់ចៀតឱកាសក្អាម គេគិតឃើញឧបាយហើយ ទើបជួលរថមានបរិវារគ្រប់ព្រមដោយថ្លៃឈ្នួល ៨ កហាបណៈ ទៅកាន់កំពង់នាវាយ៉ាងហ៊ឹកហ៊ាក់ ដាក់សន្យាទៅទិញទាំងសំពៅទុកដោយចិញ្ចៀនមួយវង់ ហើយទៅបាំងរាំងននអង្គុយនៅក្នុងទីមិនឆ្ងាយ បង្គាប់មនុស្សរបស់ខ្លួនទុកថា "កាលបើណាឈ្មួញខាងក្រៅមក ពួកអ្នកចូរធ្វើជាប្រាប់ដល់គាត់ ៗ មកទាំងនឹងដល់ខ្ញុំក៏ឲ្យបាន ៣ ត" ។

ដឹងដំណឹងថា សំពៅមក ពាណិជប្រមាណ ១០០ នាក់ មកអំពីពារាណសីដោយប្រាថ្នានឹងទទួលរបស់ នាយសំពៅប្រាប់ថា "លោកទាំងឡាយមិនបានទេ ឈ្មួញធំក្នុងទីនោះគេឲ្យបញ្ចាំទុករួចស្រេចហើយ" ។ ពាណិជទាំងនោះ ក៏ទៅរកចូឡកន្តេវាសិក ។ មនុស្សរបស់ចូឡកន្តេវាសិក ក៏បង្គាប់ដល់គ្នាឲ្យចូលទៅបែងដំណឹងឲ្យចូឡកន្តេវាសិកដឹង ដល់ ៣ តតាមដែលបានណាត់ទុក ។ ពួកពាណិជទាំងមួយរយនាក់នោះឲ្យទ្រព្យម្នាក់ៗមួយពាន់កហាបណៈជាភាគចូលហ៊ុនឲ្យសំពៅជាមួយនឹងគេ ហើយឲ្យម្នាក់ៗសុំទិញហ៊ុនរបស់គេទៀត ធ្វើទំនិញឲ្យជារបស់ខ្លួនតែមួយចំណែក ។ ចូឡកន្តេវាសិកកាន់យកទ្រព្យ ២ សែនកហា-

បណ្ណាការមកកាន់ពាណិជដោយត្រិះរិះឃើញថា ខ្លួនគួរជាអ្នកកតញ្ញូ ទើបឲ្យជញ្ជូនទ្រព្យមួយសែនកហាបណៈចូលទៅកេសេដ្ឋី ។ សេដ្ឋីសួរថា “នែបា ! ទ្រព្យនេះចៅរកបានយ៉ាងណា ? ” គេជំរាបថា “ខ្ញុំបាទតាំងនៅក្នុងឧបាយដែលលោកមានប្រសាសន៍ រកបានក្នុងរវាង៤ខែនេះឯង” ហើយក៏ជំណាលរឿងទាំងពួង ចាប់ដើមតាំងអំពីឃើញកណ្ដុរងាប់ ។ ចូឡកសេដ្ឋីត្រិះរិះថា “ឥឡូវមិនគួរបណ្ដោយក្មេងបែបនេះ ឲ្យធ្លាក់ទៅក្នុងកណ្ដាប់ដៃអ្នកដទៃទៅទេ” ហើយក៏លើកបុត្រីដែលមានវ័យចំរើនឲ្យជាគូ ប្រគល់ឲ្យជាម្ចាស់របស់ទ្រព្យទាំងអស់ ។ លុះអំណើះអំពីសេដ្ឋីទៅ គេក៏បានទទួលដំណែងសេដ្ឋីក្នុងព្រះនគរនោះ ។

រឿងនេះ ទោះបីជារឿងបរម្បរាមានសណ្ឋានការណ៍ក្នុងផ្ទៃរឿងខ្លះដូចជាមិនគួរនឹងប្រព្រឹត្តទៅបានក្នុងសម័យនេះ ព្រោះផ្សេងសម័យគ្នាក៏ពិត ប៉ុន្តែរឿងនេះគង់លាតត្រដាងឲ្យឃើញសេចក្ដីពិតខាងមួយកន្លែងដែរ ដែលគង់ជាសេចក្ដីពិតឋិតនៅ គ្រប់សម័យមិនបានផ្លាស់ប្ដូរ គឺសេចក្ដីពិតត្រង់ដែលថា :

“អ្នកប្រាជ្ញយល់ការណ៍ រមែងតាំងខ្លួនបានដោយទ្រព្យជា
ដើមទុនសូម្បីតិចតួច ដូចគេបង្កាត់ភ្លើងដែលតូច ដូច្នោះ ។

(ចូឡកសេដ្ឋិជាតក អប្បមាទវគ្គឯកនិបាត)

# រឿងសៅរសោយ

( សិរសោរជាតក )

## ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្រោយសាស្ត្រាស្លឹករឹត

( តមក )

---

សោយស្រេចស្ដេចប្រគល់ នូវសំណល់សល់នោះណា
ពួកស្នំនាំយាត្រា ថ្វាយកញ្ញាធីតាស្រី
រៀបរាប់សព្វកិរិយា ការគោក្ដាមហាចក្រី
ព្រះនាងផ្សៀងស្ដាប់ខ្មី ហើយក្សត្រីថ្វីពិនិត្យ ៗ
ទតអស់ភ័ស្ដុចំណី យល់សេចក្ដីតាមន័យពិត
សុទត្ត័រតន៍វរមិត្ត នាងគន់គិតក្នុងចិត្តថា
"អ្នកនេះ ចះចាប់សោយ នូវព្រះស្ងោយដោយរាបសា
ដូចជាព្រះបិតា នៃអាត្មាអញឯងស្មោះ ៗ
នេះជាក់មិនអ្នកខ្សត់ មិនទុរគតអំណត់សោះ
រូបប្រាណក៏គ្មានខ្ចោះ មើលមិនទាស់ភ្នែកសោះណា
គួរជាកូនមហាក្សត្រ មានសម្បត្តិកាត់បេស្ដា
ព្រោះគ្រប់សព្វកិរិយា បង្ហាញថាជាមហាក្សត្រ" ៗ
គិតក្មាងនាងស្រដី ឲ្យទាសីឃ្មាតខ្មាត
បោសលាងពេងគ្រួថ្វាត់ ហើយចាត់ក្រាលកំរាលផង

ស្រេចស្រាប់ទើបរៀបចំ ទីបន្ទំសមគន្ធ
ថ្វាយថ្វាត់ក្បែតប្បាស់ប្បន តាមបំណាន់ផងក្បែ ៗ
លុះលន់យន់ជិតយប់ នាងត្រឡប់ប្រាប់ទាសី
ឲ្យសើរើចេញខ្ចី នូវកំពលក្រាលចេញថ្វាត់
ឲ្យទុកនៅដដែល តែកន្ទេល ១ ថ្វាយក្បែ
លុះលន់យប់យន់ស្ងាត់ ទើបវារ៉ែតន៍បាត់ទាសី ៗ
ឲ្យចូលទូលថែចាំ ប្រលោមអង្គវង្សប្រក្រី
ព្រះអង្គទ្រង់ដេរស្តី ពួកទាសីក្រែកន្ទង
ព្រឹកព្រាងទើបនាងគន់ បាត់កោដនធុនស្មោហ្មង
ឲ្យស្រីទាសីផង នាំទៅផ្គងថ្វាយក្បោ ៗ
ស្តេចយល់ផលបំណាំ ទើបចក្រីទ្រង់ស្តីថា
" កោដនធុននេះណា អញកោត្តាម្តេចទៅរ៉ុ
ព្រោះហេតុគេទអាហារ សត្វប្រការទាំងនេះខ្ចី
គួរតែមនុស្សប្រុស-ស្រី ជាទាសីធីទើបសម ។
ចេះហាន់តោងប្រញាប់ យកចេញឆាប់កុំសម្ងំ"
ព្ធះប្ហះកំអស់ស្ទំ វិលបង្គំចមរល័ក្ខណ៍
ទើបអង្គអនង្គស្រី ប្រើទាសីទាំងពីរនាក់
ឲ្យចូលពោលពក់ទាក់ លោមចមចក្រដោយមាយា ៗ
ទាសីខ្ចីគំរង់ ទៅថែចង់អង្គពជា
លលេងផ្សេង ៗ គ្នា តែកជាមិនរវល់

ស្នំនោះអស់ដំរេះ  រលែក្រអេះទៅមណ្ឌល
ចូលទូលដល់និម៌ល  ឲ្យទ្រង់យល់ផលនេះនៃ ។
"បពិត្រវរមិត្តពៅ  សូមយាងទៅឆាប់ៗវៃ
ដ្បិតគាត់ក្រោធខ្លាំងក្រៃ  គួរឲ្យភ័យក្រៃប្រមាណ
កាលគាត់យល់នាងហើយ  គាត់គង់ស្បើយល្ហើយពុំខាន
ហើយនាងគង់ទង់បាន  ពោលស្មោះស្មានតាមចិន្តា" ។
ក្សត្រីស្រីវរលក្ខណ៍  ទ្រង់ស្ដាប់ដាក់ដូច្នេះណា
នាងយកពរពស្ត្រា  តែងកាយាល្អប្រិមប្រិយ
លាបប្រេងតែងដោយម្សៅ  ហើយនាងហៅនូវតាសី
លីលាម្មីម្មាទ្វី  ហៃក្សត្រីស្រីកល្យាណ ។
លុះដល់យល់បរម  ទើបប្រណម្យបង្គំបាន
ទសពលយល់កល្យាណ  ចូលមកប្កានហានបក្រី
ស្ដេចអរអំណរសល់  ទើបទសពលបន្ទូលទ្វី
"ហៃប្អូនស្ងួនប្រិមប្រិយ  នាងប្រណីបងណាស់ណា ។
នៅនាគ្រាលើកមុន  នាងធ្វើគុណធ្ងន់ខ្លាំងក្លា
លុះក្រោយស្រីធីតា  ធ្វើទោសាឲ្យបងខឹង
ឲ្យបងវង្វាស់គេ  ទុក្ខសែនទ្វណាព្រលឹង
តែទោះអស់ទាំងម៉ឺន  បងក៏ខឹងស្រីពុំបាន ។
បងនៅតែនឹកគិត  ថាវរមិត្តរ័តន៍ក្សត្រក្សាន្ត
មានគុណពន់ប្រមាណ  ប្រៀបពុំបានទេប្អូនស្រី

ព្រោះបងកំពុងព្រួយ បានស្រីជួយស្រួយឡើងខ្ញី
ឲ្យបានក្សាន្តសុខី សព្វាកត្រីទិនទិវ ។
បងត្រូវតែតបស្នង គុណនួនល្អងពុំរង់ក
តែដ្បិតបុត្រករិយា ញាតិនានារបស់បង
ព្រាត់ទៅគ្មាននៅជិត ចេះវាមិត្តអាណិតផង
កុំបីស្រីមួហ្មង ឲ្យខ្លួនបងនៅផងណា ! ៗ
ថ្ងៃក្រោយបងនឹងធ្វើ សព្វអំពើតាមធីតា
សងគុណគុនវិញណា លុះដល់គ្រាដីរ៉ាក្ស័យ ”
សុទត្តតែនកញ្ញា ស្តាប់រាចាមហាក្សត្រថ្ងៃ
ទើបថ្នមលោមព្រះទ័យ ឲ្យជៀសដ័យបានក្តីស្បើយ ៗ
“បពិត្រព្រះបក្រី សូមប្រណីថ្ងៃខ្ញុំអើយ
កុំក្រោធពិរោធឡើយ ខ្ញុំខុសហើយណាព្រះបង
ព្រះស្មោយសោយគ្រប់មុខ ខ្ញុំចាត់ទុកស្រេចជាម្តង
មួយទៀតប៉ព្រះបង ទ្រង់ប៉ុនប៉ងបំណងអ្វី ៗ
គង់បានតាមប្រាថ្នា ដូចចិន្តាណាចក្រី
ខ្លួនខ្ញុំព្រមទាសី នឹងឃ្លាតខ្ញុំគ្រប់វេលា ”
សុទត្តនឹងក្សត្រថ្ងៃ ត្រាស់ប្រស្រ័យគ្នានឹងគ្នា
ពន្ទេបរាជមាយា តបតគ្នាជាហេតុន័យ ៗ
ពេលនោះស្រស់បវរ ញាំងក្ខួចឲ្យអរក្រៃ
តម្រែកត្រេកព្រះទ័យ ហើយស្រីថ្ងៃវៃទូលថា

"ខ្ញុំម្ចាស់សូមបមបក្រ ឡើងដំណាក់ស្នាក់កាយា
ហើយទ្រង់គង់សុខា តាមប្រាថ្នាណាព្រះបង" ។
ស្តាប់បប់នរបតី នាំក្សត្រីខ្ទិតវង់
ឡើងគង់កន្លែងម្តង តាមបំណងផងកល្យាណ
ដល់ក្លាន្តនាងក្សត្រី លើកចំណីថ្វាយក្សត្រក្សាន្ត
ស្តេចសោយព្រះស្ងោយថ្កាន ហើយទើបបានចូលរួមកាយ ។
រួមផ្ទំនឹងម៉ុមស្រី ស្រស់ពិសីស្រីឆោមឆាយ
ផ្តេកផ្តិតប្រតិតកាយ សុខសប្បាយឥតបីហ្មង
កាលណោះស្រស់ក្សត្រី សួរស្វាមីដោយទំនង
"ខ្ញុំម្ចាស់សូមព្រះបង ប្រាប់ដើមទងប្អូនផងក៏ ។
ហេតុម្តេចក៏ស្តេចចាក មកលំបាកយ៉ាកអាត្មា
ទុរគតខ្សត់ប្ចេះណា សូមក្សត្រាប្រាប់ប្អូនផង"
ស្តេចស្តាប់ស័ព្ទនិរមល ទើបទសពលបន្ទូលស្នង
ប្រាយប្រាប់សព្វដើមទង តាមទំនងពុំលាក់ឡើយ ។
ថា "ឱ! គួរឲ្យសៅ សូនឆោមឆ្មៅពៅបងអើយ
បងនឹករំពឹកហើយ ទ្រង់គ្មានស្បើយល្ហើយទេស្រី
កាលបងគ្រងសម្បត្តិ ជាមហាក្សត្រក្តាត់បារមី
សេនាមហាករី កស្តមទ្រៃក្រកទួង ។
កាលនោះអស់ហោរា មើលជតាអាត្មាបង
ពិនិត្យពិតហើយហោង ទើបហោរផងផ្គងទូលខ្ញុំ

ថា "មានព្រះសៅរ៍សុទ្ធ ជាទេវបុត្រផុតបារមី
បាកពីសួគ៌ាស្រី ដែកបារមីនៃបងណា ។
បងអាងកម្លាំងខ្លួន មិនតាមធ្មនក្បួនហោរា
អាងច្បាំងអាងខ្លាំងក្លា អាងចេស្តាបារមីថ្កាន
ប្រឹងប្រែងតែតែងពល ចាំតទល់ឲ្យដល់ប្រាណ
ព្រោះគិតគំនិតស្មាន ថាសៅរ៍មានសណ្ឋានអគ្គ ។
គិតកែតែរៀបទ័ព គ្រឿងប្រដាប់គ្រប់ផ្ចិតផ្ចង់
គិតថាបើឃើញអង្គ នឹងតំរង់ប្រឡងយុទ្ធ
តែលុះថ្ងៃនោះណា ក្បួនះហោរាហៅមហាធុត
ព្រោះត្រូវសៅរ៍ទេវបុត្រ ចាកច្បុតផុតសួគ៌ា ។
មកបិតដួងចិត្តបង ពិតជាម្តងណាល្អងក្លា
ហេតុតែពៀរវេរា កម្មនានាពីមុនខ្ចី
ឲ្យបងវង្វេងប្រាណ ភ្លេចសីលទានគ្មានដឹងអី
ភ្លេចខ្លួនសូន្យស្មារតី ដេញកាប់ខ្ចីតែពលឯង ។
ចេញពីទីសីមា តែឯកាមហាបំបែង
កណ្តោបខ្លោបកណ្តែង ភ្លេចកន្ទ្វែងវង្វេងជាន
ពុំយល់ស្គាល់មាគ៌ា ដែលលីលាយាត្រាថ្កាន
វិលទៅលំនៅឋាន វែងព្រួយប្រាណប្រមាណក្រៃ ។
ជាប់មកទឹងអាត្មា តែទ័នថ្វាកំដរដៃ
មកុដមាសទុកាសក្រៃ នឹងសេះថ្ងៃ ៣ នោះណា

ទឹកទៀតមិនបង់ស្តី    គ្មានបំណីអ្វីគោក្តា
ត្រាច់លង់ក្នុងព្រឹក្សា    យូរទៅក៏ទើបផុតព្រៃ ៗ
បានដល់វាល ១ ក្បូរ    មានស្រែស្រូវនៅច្រើនក្រៃ
មានប្រុស ១ នោះនៃ    មករំពៃចាំស្រូវហោង
ហើយមានឆ្កែ ១ ណា    ចាំបាយវាអស់ជាមួង
វាបែរឃើញឯបង    ទើបវាយចង់បង់ខ្ញាំងក្បា ៗ
វាថាបងនេះខ្មី    ល្ងបបាយត្រីធីគោក្តា
វាហោទបំពោតថា    ឯបងណាឥតដឹងសោះ
រីមកុដផុតដួងចិត្ត    ក្លាយទៅពិតឥតមានខ្វោះ
ជាសំណុំបាយស្អោះ    កម្មអ្វីម្ល៉ោះណាស្រស់ស្រី ៗ
ឃើញហេតុគេទំហុត    បងដោះមកុដរតន៍ពិសី
ឲ្យវាជាស្រេចខ្មី    វាប្រណីលែងវាយបង
ចេញពីទីនោះទៅ    ដោយមុខខ្មៅសែនសៅហ្មង
លំបាកយ៉ាកកន្ទង    ព្រោះកម្មបងណា៎ល្អងណា៎ ៗ
គិតថាពុំយូរឡើយ    គង់បានស្បើយល្ហើយ។ព
តែកម្មចាំផ្តាសា    ឲ្យទុក្ខាទៀតជាមួង
មានចោរឯណាក្បូរ    ល្ងចំប្រូតស្រូវយកទៅហោង
ម្ចាស់ស្រែឃើញឯបង    វាវាយចង់ឥតប្រណី ៗ
ព្រះខ័ន្ធកាន់នោះវា    ក្លាយទៅជាកណ្តៀវខ្មី
ឃើញឆ្នោះបងអស់ស្តី    ផលកម្មអ្វីក្រៃច្នេះណា

ក៏បានព្រះច័នហើយ ទើបក៏ស្បើយល្ហើយទោសា
បងបានក្បាន្តទុក រូបដក់ ១ គ្រាទៀត ។
បងកើបទៅមុខ . ទំរែកលុករុកជ្រែកជ្រៀត
តែកម្មចាំឈូបច្នៀត មកបៀនបៀតទៀតណាស្រី
មនុស្សម្នាក់ស្ទាក់ចាប់បង ហើយកយបងបងឥតបី
ថាបងជង់អប្រិយ ជាចោរខ្ចួលួចគោក់ ។
រីសេះទីនាំងពិត ល្អពេញចិត្តឥតគណនា
ប្រែកាយក្លាយទៅជា គោផង់ក៏ប្រាកដជាក់
លុះក៏បានសេះហើយ ទើបក៏ស្បើយល្ហើយទោសៈ
ខ្លួនបងធ្ងន់មរណៈ រួច ១ វគ្គណាកល្យាណ ។
បងកើបរយ៉ាគ្រា អនាថាឯកាប្រាណ
យូរសល់ទើបដល់ឋាន អាពាមមានលោកប្រើនក្រៃ
បងចូលទូលថេរៈ សូមលោកកាក់ស្នាក់អាស្រ័យ
ទៅនោះលុះយូរថ្ងៃ លោកកៃកែខ្ចលបងជា ។
ខ្លួនបងបងបួសស្នាក់ ទៅពឹងពាក់ព្រះសាសនា
ព្រះសង្ឃអគ្គសាវកា កំករុណាមគ្គាបង
តែកម្មចាំផ្ទួន ពុំឃ្លាតឃ្លាឆ្ងាយជាមួន
មុនបួសនោះខ្លួនបង យកគ្រឿងផងទៅបោកគក់ ។
ដាំឆ្នាំងតាំងក្រោកខ្វះ រំងាស់ស្លោរហើយជ្រលក់
ប្រចាច់ឈ្មួចញីញក់ រលំកែងឯក្រៅវត្ត

ពេលនោះប្រុស ៥ នាក់    ចូលគគាក់មកឆាក់ទាក់
ដាល់បងចងរាយរាត់    ហោមឡោមព័ទ្ធឥតប្រណី ៗ
រះថាខបំពោតថា    បងនេះណាមហាអប្រិយ
ជាចោរលួចគោខ្ញី    ឃើញសក្ខីនៅដៃច្បាស់
ហេតុតែពៀរអកុសល    តាមឲ្យផលយល់រហ័ស
ចីវរក៏ក្រឡុះ    ជាបន្ទុះស្បែកគោរ៉ា ៗ
រ៉ារ៉ាយបងឥតលោះ    តែពេលនោះចួនគ្រោះជា
បានសង្ឃគ្រប់អង្គ    ជួយធានាទើបរលែង
ខ្ពួបងពងជាលដំ    សង្ឃតូចធំជួយជ្រោមជ្រែង
ថែទាំថ្នាំប្រដែង    អស់កាលវែងទើបបងជា ៗ
ទ្រាំនៅតែទៅមុខ    ក្រែងពុំសុខទុក្ខអង្គ
ទើបបងផ្គងវន្ទា    សង្ឃនានាលាយាត្រា
ត្រាច់ចរយូរតិចទៅ    ដល់លំនៅខ្ទមយាយតា
សូមពាក់ស្នាក់អាត្មា    ពីរយាយតាមិនថាអ្វី ៗ
បងស្នាក់ពាក់ទីនោះ    តែគឺមោះគ្រោះអប្រិយ
ព្រឹកព្រាងស្រាងឡើងខ្ញី    បងឥតបីស្មានឡើយហោង
គ្រាប់ពូជផងយាយតា    បាត់ទៅណាអស់ជាមួង
តាយាយស្ដាយគន្ធង    ទើបតែកបងតួកាយា ៗ
ពេលនោះទម្រង់ពេជ្រ    ផែលចងរេចជាយកូសា
ក្លាយដូចគ្រាប់ពូជណា    ទើបយាយតាក្រោធាក្រៃ

ចាប់បង់សំពង់ធំ　　រាយដាក់ប្រំឥតសំច័យ
អស់ចិត្តលុះល្ហិតល្ហៃ　　ទើបឆាកដៃលែងរាយបង់ ។
បានពូជហើយក៏ដេញ　　ឲ្យបង់ចេញពីនោះហោង
បង់ក្រំជាំពុរពង់　　មុខមួយហ្មង់កន្ទង់ក្រៃ
បង់សោតក៏អត់ឃ្លាន　　ដើរសូមទានគ្រាន់អាស្រ័យ
កាត់ដងរំលងព្រៃ　　ស៊ើរៗក្ស័យណាថ្ងៃអ៊ើយ ។
ហេតុគុណបុណ្យកុសល　　បង់បានដល់យល់គ្រាណត្រើយ
អស់ទុក្ខបានសុខស្បើយ　　ទ្រង់ល្ហៃល្ហើយព្រោះប្អូនស្រី”
ស្ដេចថ្លែងថែងហេតុផល　　ប្រាប់និរមលឥតសល់អ្វី
បានជាបសត្វសេចក្ដី　　ក៏ក្សត្រីអស់សង្កា ។

(មានត)

វាទ:របស់អ្នកប្រាជ្ញជប៉ុនឈ្មោះ កិនយ៉ូអូតា :

“នៅក្រោមឋានសួគ៌ (គឺមនុស្សលោក) នេះ មានមហា-សម្បត្តិដ៏សំខាន់យ៉ាងក្រៃលែង ៣ ប្រការ គឺ ករិយា, កាំភ្លើង, ព្រះសង្ឃ” ។

ប្រែចាកទស្សនាវដ្ដីខាវសាសនាភាសាថៃ

អ្នកប្រែ: ចាប - ពិន

# រឿងសាមកុក

## កណ្ឌទី ២១

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាតបើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្ដានស្នេហាជាតិ ។

ចូឆូជជិកសួរថា បើខ្លួនមិនបានទៅប្រឹក្សាគ្នានៅផ្ទះតាំងស៊ុនទេ ចុះក្រែសដែលសរសេរអក្សរទឹងឈាមនោះ សេចក្ដីដូចម្ដេចខ្លះ? ។ នាហ្មឺនទាំង ៤ នាក់ឆ្លើយថា ក្រែសដែលសរសេរសេចក្ដីដូចម្ដេចខ្លះ នោះខ្ញុំបាទមិនបានដឹងឃើញទេ ។ ចូឆូក៏បង្គាប់ឲ្យយកខ្លួនខេងតងដែលជាបាវតាំងស៊ុននោះចេញមកប្រទល់មុខគ្នា ខេងតងក៏ឆ្លើយថា នាហ្មឺនទាំង ៤ នាក់នេះហើយដែលបានទៅរួមគំនិតគិតគ្នាលើផ្ទះតាំងស៊ុន ។ នាហ្មឺនទាំង ៤ មិនទទួល ។ ខេងតងឆ្លើយថា ដើមដំបូងជូហុកទៅរកតាំងស៊ុនមុន លុះដូឡាន, តាំងអ៊ុប, ង៉ោហួន, ម៉ាថេងឡើងទៅក្រោយ ជូហុកខ្លាចក៏ស្ទុះចូលទៅពួនក្នុងកាំងនន រួចតាំងស៊ុនយកឡាយព្រះហស្ត

ដែលសរសេរនឹងក្រែសនោះមកឲ្យមើល ហើយនិយាយគ្នាព្រមរួមគំនិត គិតការនោះថា នឹងធ្វើអន្តរាយដល់មហាឧបរាជ ដូហ៊ុកទើបចេញមកនិយាយជាមួយគ្នាទៀត តាំងស៊ុននឹងនាហ៊ឺន ៥ នាក់ ក៏ធ្វើសំបុត្រចុះនាមទុកជាមួយគ្នា ហេតុម្ដេចអ្នកទាំង ៤ នៅមិនទទួល? ។ ដូហ៊ុកដំរាបចូឆូថា ខេងតង់នេះលបសហាយនឹងករិយាតូចតាំងស៊ុន លុះតាំងស៊ុនចាប់បានឲ្យវាយផ្ចាលរួចដាក់ច្រវាក់ទុក ខេងតងមានចិត្តអាឃាតព្យាបាទតាំងស៊ុន លួចរត់មកបាន ក៏យកសេចក្ដីបង្កាច់មកប្ដឹងពោលទោសតាំងស៊ុនថានឹងគិតប្រទូសរ៉ាយមកមហាឧបរាជ សូមកុំឲ្យមហាឧបរាជជឿស្ដាប់ពាក្យវាជាមនុស្សអាក្រក់ ។

ចូឆូថា ព្រោះខ្លួនវាមិនបានចូលគំនិតគិតជាមួយនឹងខ្លួនរាល់គ្នាបានជាខ្លួនថាវាជាមនុស្សអាក្រក់ ឯត្រង់តាំងស៊ុនគិតឲ្យកៀតប៊ុងយកថ្នាំពិសមកឲ្យយើងផឹក នោះខ្លួនទាំង ៤ នាក់ដឹងឮឃើញដែរឬទេ? ។ នាហ៊ឺនទាំង ៤ ក៏ឆ្លើយថា ខ្ញុំបាទមិនបានដឹងទេ ។ ចូឆូថា "រឿងទាំងអស់នេះខ្លួនមិនទទួលដឹងសោះ បើដូច្នោះយើងនឹងស៊ើបសួរគេទៅទៀត បើបានសេចក្ដីដូចយើងដឹង យើងនឹងប្រហារជីវិតខ្លួនទាំង ៤ នាក់ចេញ" ថាហើយក៏បង្គាប់ទាហានថា វេលានេះយប់ហើយ ឲ្យយកនាហ៊ឺន ៤ នាក់ទៅដាក់គុកទុកឲ្យខ្ជាប់ខ្ជួន ។ ទាហានក៏ចាប់ខ្លួននាហ៊ឺនទាំង ៤ ទៅធ្វើទោសតាមបង្គាប់ចូឆូ ។

លុះព្រឹកឡើង ចូឆូក៏នាំទាហានទៅសួរតាំងស៊ុនឯផ្ទះ តាំងស៊ុនដឹងក៏ចេញមកទទួលចូឆូឡើងទៅអង្គុយទីសមគួរ ។ ចូឆូក៏សួរតាំងស៊ុនថា

ពីម្សិលមិញៈយើងឲ្យមកអញ្ជើញអ្នកទៅស៊ីលៀង ហេតុម្ដេចបានជាអ្នកមិនទៅ? ។ តាំងស៊ុនឆ្លើយតបថា ខ្ញុំបាទឈឺមិនទាន់ជា ទើបនឹងទៅក្រែងពេកបណ្ដាលឡើងវិញ ។ ប៊ូឆ្គសួរថា ដែលអ្នកឯងថាឈឺនោះ យើងក៏ដឹងអស់ហើយ មិនមែនឈឺដោយពេកអ្វីក៏ទេ គឺអ្នកឯងឈឺចិត្តដៀតគិតការមិនសម្រេចដូចប្រាថ្នា ។ តាំងស៊ុនបានស្ដាប់ដូច្នោះ ក៏ភ័យស្ងុតស្មារតីមិនឆ្លើយថាដូចម្ដេចសោះ ។ ប៊ូឆ្គក៏សួរតាំងស៊ុនថា សេចក្ដីដែលកៀតប៊ុនគិតធ្វើប្រទូសរ៉ាយដល់យើងនោះ អ្នកឯងដឹងឬទេ? ។ តាំងស៊ុនឆ្លើយថា ខ្ញុំបាទមិនដឹងសោះ ។ ប៊ូឆ្គអស់សំណើចហើយថា ខ្លួនមិនដឹងក៏ជាហើយ ។ ប៊ូឆ្គក៏ប្រើទាហានឲ្យទៅនាំកៀតប៊ុនមកឯផ្ទះតាំងស៊ុន ។ កាលកៀតប៊ុនមកដល់ក្រឡេកឃើញប៊ូឆ្គ ក៏ស្រែកដេរថា អាសត្រូវពងសម្បត្តិ អាឯងឲ្យនាំអញមកនិយាយការអ្វីទៀត ។

ប៊ូឆ្គក៏និយាយនឹងតាំងស៊ុនថា ពួកម៉ាកផងខ្លួនដែលរួមគំនិតគិតការជាមួយគ្នានឹងធ្វើប្រទូសរ៉ាយយើងនោះ ៥ នាក់ ឥឡូវចាប់បាន ៤ នាក់ហើយ យើងដាក់គុកទុក តែម្នាក់ទៀតនៅមិនទាន់បានខ្លួន ។ តាំងស៊ុនថា ខ្ញុំបាទនឹងបានគប់គិតនឹងអ្នកឯណាក៏ទេ ។ ប៊ូឆ្គក៏សួរកៀតប៊ុនថា នរណាប្រើឯងឲ្យយកថ្នាំពិសទៅដាក់ឲ្យអញផឹក? ។ កៀតប៊ុនថា នរណានឹងបានប្រើអញក៏ទេ ។ ប៊ូឆ្គខឹងណាស់ឲ្យវាយកៀតប៊ុនម្ដងទៀតយ៉ាងខ្លាំង ។ តាំងស៊ុនឃើញប៊ូឆ្គឲ្យវាយកៀតប៊ុនដូច្នោះ ក៏បង្កើតឲ្យក្ដៅក្នុងចិត្តដូចអគ្គិយលើគំនរភ្លើង ។ ប៊ូឆ្គក៏សួរកៀតប៊ុនទៀតថា ពីដើមម្រាម

ដៃឯងគ្រប់ ១០ ហេតុះម្តេចនៅសល់តែ ៩? ។ កៀតប៉ុងថា អញកាត់ម្រាមដៃអញ ១ ចេញ សច្ចាស្បថថា នឹងសម្លាប់អាឯងឲ្យបាន ។

ចូឆ្ងូខឹងណាស់ ទើបបង្គាប់ឲ្យពាហានកាត់ម្រាមដៃកៀតប៉ុងអស់ទាំង ៩ ហើយ និយាយថា ឯងកាត់ម្រាមដៃអស់ ១ ឯងនៅធ្វើអញមិនបាន ឥឡូវអញឲ្យកាត់ម្រាមដៃឯងអស់ ៩ ទៀត ឯងត្រូវគិតធ្វើអញឲ្យបានតាមគំនិតឯងចុះ ។ កៀតប៉ុងថា មាត់អញនៅមានអណ្តាត អញក៏នៅល្មមនឹងជេរម៉ែអាឯងបានទៀត ។ ចូឆ្ងូក៏បង្គាប់ពាហានឲ្យកាត់អណ្តាតកៀតប៉ុង ។ ក៏ស្រែកថា អាឯងកុំធ្វើឲ្យអញលំបាកពេកឡើយ ស្រាយអញចេញចុះអញនឹងបញ្ចូញសេចក្តីទាំងអស់ឲ្យដឹង ។ ចូឆ្ងូបានស្តាប់ក៏ឃាត់ហាមពាហាន ហើយបង្គាប់ឲ្យស្រាយចំណងចេញ ។ កៀតប៉ុងក្រោកឡើងបែរមុខទៅរកព្រះបរមរាជវាំង ហើយក៏ក្រាបថ្វាយបង្គំព្រះមហាក្សត្រថា "ខ្ញុំទូលព្រះបង្គំជាខ្ញុំផែនដី ឥឡូវមានអាខ្មាំងសត្រូវវាធ្វើឲ្យចលាចលដល់រាជសម្បត្តិ ទូលព្រះបង្គំជាខ្ញុំគិតនឹងទំនុកបំរុងផែនដី ដើម្បីបំផ្លាញរំលាយអាខ្មាំងឲ្យបានតែមិនសមតាមសេចក្តីប្រាថ្នា" ថាហើយក៏បោកក្បាលនឹងសសរសិលាបែកស្លាប់នៅទីនោះ ។ ចូឆ្ងូឃើញដូច្នោះ ក៏ឲ្យពាហានពន្លះសាច់កៀតប៉ុងចេញជាដុំ ។ ហើយកាត់ក្បាលយកទៅដោតផ្គាលកណ្តាលផ្លូវជាទីប្រជុំជន ។

ហើយចូឆ្ងូក៏ប្រើពាហានទៅយកខ្ទួនខេងតងមក ហើយសួរតាំងស៊ុនថា អ្នកឯងស្គាល់ឈ្មោះអានេះឬទេ? ។ តាំងស៊ុនឃើញខេងតងច្បាស់ក៏ទឹកខឹងណាស់ ទើបប្រាប់ចូឆ្ងូថា "អានេះជាបាវខ្ញុំបាទជា

មនុស្សទុរជន  គិតប្រទូសរ៉ាយលួចប្រពន្ធខ្ញុំបាទ ។ នឹងទុកវាមិនបាន "
ហើយតាំងស៊ុនក៏ហូតក្របីលើកឡើងនឹងកាប់ខេងគង់ ៗ  ប៉ូចូក៏ឲ្យទា-
ហានដណ្តើមយកក្របីបាន  ហើយនិយាយថា  ខេងគង់នេះជាដើមហេតុ
ទៅពោលទោសថា  ខ្លួននឹងនាហ្មឺនមានឈ្មោះ ៥ នាក់  រួមគំនិតគិតគប់
គ្នានឹងប្រទូសរ៉ាយយើង  ឯនាហ្មឺនដែលនៅក្នុងក្រុង ៤ នាក់នោះយើង
ចាប់ខ្លួនបានហើយ  បានពិចារណាសួរក៏ឆ្លើយទទួលតាមពាក្យសត្យ,
ដែលខ្លួនមកធ្វើជាចិត្តគិតសម្លាប់ចោលផងខ្លួនចេញនោះ  ខ្លួនគិតនឹងបំ-
បាត់កស្ដុតាងសូន្យទៅឬ ៗ  តាំងស៊ុនថា  ខ្ញុំបាទនឹងបានគប់គិតនឹង
អ្នកឯណាប៉ងប្រទូសរ៉ាយលោកក៏ទេ ៗ

ប៉ូចូក៏បង្គាប់ទាហានឲ្យឡើងទៅរើមើលលើផ្ទះតាំងស៊ុន បានសំបុត្រ
ដែលសរសេរចុះព្រះនាមហោយេលោហ៊ិតនឹងព្រែស  ហើយនឹងសំបុត្រ
ដែលចុះឈ្មោះសញ្ញាសច្ចាស្បថនឹងគ្នានោះ នាំមកឲ្យប៉ូចូទទួលយកមក
មើលសំបុត្រទាំង ២ ច្បាប់ ក៏ដឹងច្បាស់ជាសំបុត្រក្នុងព្រែសនោះជាឡាយ
ព្រះហស្ដព្រះចៅហៀនតេ តាស់បង្គាប់ឲ្យធ្វើ  សំបុត្រដែលសញ្ញាចុះ
ឈ្មោះនោះមានឈ្មោះឡៀវពីផង  ហើយប៉ូចូថា "អាពួកនេះឧបមាដូច
ជាសត្វតិរច្ឆាន  គួរឬមកគិតប្រទូសរ៉ាយអញ"  ទើបឲ្យទាហានរឹបយក
របស់ទ្រព្យតាំងស៊ុនអស់ពីលើផ្ទះ  ហើយឲ្យចាប់យកខ្លួនតាំងស៊ុននឹង
ភរិយាបុត្រស្ត្រីបក្សពួកទាំងប៉ុន្មាន  នាំទៅដល់ផ្ទះប៉ូចូ ៗ ក៏យកសំបុត្រ
ទាំង ២ ច្បាប់នោះបង្ហាញឲ្យទីប្រឹក្សាទាំងពួងមើល  ហើយថា ព្រះចៅ
ហៀនតេគិតឲ្យធ្វើប្រទូសរ៉ាយយើងជាអ្នកមានគុណបំណាច់  ឥឡូវយើង

ត្រូវនិរទេសចេញពីរាជសម្បត្តិ ចាត់យកពូជព្រះរាជវង្សដែលមាន សតិបញ្ញាមកតាំងជាម្ចាស់ផែនដីជំនួសវិញ តើអ្នកទាំងអស់គ្នានឹងយល់ឃើញប្រការម្ដេច? ។

ចៀយ៉ុកឆ្លើយថា សព្វថ្ងៃនេះរាជការក្នុងទីក្រុងនឹងសាលាខែត្រខាងក្រៅទាំងពួង ក៏ជាកម្មសិទ្ធិនៃលោក ព្រោះលោកធ្វើការអ៊ឹកកាន់យកព្រះរាជតម្រាស់ព្រះចៅហៀនតេជាប្រមាណ នាហ្មឺនសព្វមុខមន្ត្រីក្នុងក្រុងនឹងខែត្រក្រៅ ក៏នៅកោតក្រែងបង្អាប់បញ្ញាលោកទាំងអស់ គ្រានេះផែនដីក៏នៅមិនទាន់ពបទាប ដែលលោកនឹងឲ្យនិរទេសព្រះចៅហៀនតេចាករាជសម្បត្តិនោះ បើដឹងទៅដល់សាលាខែត្រខាងក្រៅហើយ ក៏គង់នឹងលើកកងទ័ពចូលមកវាយប្រសព្វគ្នា ធ្វើអន្តរាយដល់លោកៗ ក៏នឹងមានសេចក្ដីលំបាក, ដែលខ្ញុំបាទជំរាបលោកដូច្នេះ សូមឲ្យលោកត្រិះរិះមើលតាមការណ៍គួរចុះ ។

ចូឆូយល់ត្រូវផង ក៏បង្គាប់ទាហានទាំងពួងឲ្យទៅចាប់កិរិយាបុត្រនឹងបក្សពួកនាហ្មឺន ៤ នាក់នោះនាំមក ហើយឲ្យយកខ្លួនតាំងស៊ុនទីងនាហ្មឺន ៤ នាក់ នូវកិរិយាបុត្រស្រីត្រីបក្សពួក ប្រហែល ៧០០ ប្លាយនាក់ទៅប្រហារជីវិតក្រៅកំពែងក្រុងហ៊ូតោ ។ នាហ្មឺនមុខមន្ត្រីនូវសាលាប្រជារាស្ត្រទាំងឡាយឃើញដូច្នោះ ក៏មានសេចក្ដីអាណិតអាណាថយំផែកស្រក់ទឹកភ្នែកពល់គ្នាៗ ខណៈកាលចូឆូសម្លាប់តាំងស៊ុនទីងបក្សពួកចេញអស់ហើយ ក៏នៅមិនអស់កំហឹង ទើបស្មៀតក្របីចូលទៅក្នុងព្រះបរមរាជវាំង ប្រាថ្នា

ដើម្បីទឹងសម្លាប់នាងតាំងគុយហ៊ុយជាប្អូនតាំងស៊ិន ដែលជាព្រះស្នំព្រះចៅហៀនគេ ។

ចំណែកព្រះចៅហៀនគេត្រាស់ប្រឹក្សាទឹងព្រះនាងហុកហៅ ជាព្រះអគ្គមហេសីទឹងនាងតាំងគុយហ៊ុយថា ''យើងឲ្យសំបុត្រទៅតាំងស៊ិនជាយូរខែហើយ នៅមិនទាន់បានសេចក្ដីជាយ៉ាងម្ដេចសោះ'' ទទួលក្រឡេកទៅឃើញប៉ូធ្វូសៀតក្រប៉ដើរចូលមក ព្រះចៅហៀនគេស្លុតព្រះទ័យភ័យណាស់ មិនបានត្រាស់ជាប្រការម្ដេច ។ ប៉ូធ្វូមិនបានថ្វាយបង្គំតាមសមគួរ ក៏និយាយទូលព្រះចៅហៀនគេថា តាំងស៊ិនគិតប្រទូសរ៉ាយទូលព្រះបង្គំជាខ្ញុំ ព្រះអង្គទ្រង់ជ្រាបឬទេ ? ។ ព្រះចៅហៀនគេបានស្ដាប់ប៉ូធ្វូសួរដូច្នោះ ទើបក្លែងត្រាស់ថា តាំងគុះធ្វើការអាក្រក់ទឹងផែនដី គេបបួលគ្នាសម្លាប់ចេញហើយ ហេតុម្ដេចមហាឧបកជមកថាតាំងគុះគិតប្រទូសរ៉ាយទៀត ។ ប៉ូធ្វូទើបស្រែកយ៉ាងខ្លាំងថា ទូលព្រះបង្គំទូលថា តាំងស៊ិនគិតប្រទូសរ៉ាយដល់ទូលព្រះបង្គំជាខ្ញុំ ហេតុម្ដេចទ្រង់យករឿងតាំងគុះដែលស្លាប់ទៅហើយនោះមកប្រាប្តវិញដូច្នេះ? ។ ព្រះចៅហៀនគេបានឮប៉ូធ្វូស្រែកដូច្នោះក៏ស្លុតព្រះទ័យហើយត្រាស់ថា តាំងស៊ិនគិតប្រទូសរ៉ាយប្រការម្ដេចនោះយើងមិនបានដឹងទេ ។ ប៉ូធ្វូថា ព្រះអង្គសរសេរអក្សរដោយលោហិតឲ្យទៅតាំងស៊ិននោះភ្លេចអស់ហើយឬ? ។ ព្រះចៅហៀនគេក៏មិនត្រាស់តបថាប្រការម្ដេច ។

ប៉ូធ្វូក៏បង្គាប់ពេជ្ឈឃាដឲ្យចាប់នាងតាំងគុយហ៊ុយ ដែលជាប្អូនតាំងស៊ិនយកទៅសម្លាប់ ព្រះចៅហៀនគេត្រាស់ថា នាងតាំងគុយហ៊ុយ

មានគតិបាន ៤ ខែមកហើយ មហាឧបរាជចូរឈ្វេងយល់មកដល់យើង កុំបីសម្លាប់នាងនោះឡើយ ។ ចូធូថា ព្រះអង្គឲ្យតាំងស៊ុនគិតប្រទូសរ៉ាយទូលព្រះបង្គំជាខ្ញុំ ដោយសារមានទេពតាជួយទូលព្រះបង្គំជាខ្ញុំ ទើបបានដឹងការចាំងតួងមិនឲ្យទូលព្រះបង្គំជាខ្ញុំដល់នូវសេចក្ដីស្លាប់ ប្រសិនព្រះអង្គនឹងយកស្រីម្នាក់នេះទុកតទៅមុខ គង់នឹងមានអន្ដរាយដល់ទូលព្រះបង្គំជាខ្ញុំពុំខាន ។ ព្រះនាងហុកហៅអគ្គមហេសីមានព្រះសវនីយ៍នឹងចូធូថា មហាឧបរាជអាណិតទៅចុះកុំអាលសម្លាប់នាងតាំងគុយហ៊ុយឡើយ ចូរយកទៅដាក់គុកទុកក្នុងផ្ទះត្រជាក់សិន បើប្រសិនប្រសូតបុត្ររួចកាលណាសឹមសម្លាប់ចេញចុះ ។ ចូធូតបថា នឹងយកឈាមសរសៃរ៉ាក់ទុកធ្វើអ្វី បើបុត្រវាធំឡើងវាក៏មិនលែងធ្វើបាបព្យាបាទប្រទូស-រ៉ាយដល់ទូលព្រះបង្គំឡើយ ។ នាងតាំងគុយហ៊ុយក៏អង្វរករចូធូថា បើមហាឧបរាជមិនទុកជីវិតខ្ញុំទេ សុំកុំឲ្យកាប់ខ្ញុំនឹងអាវុធឲ្យលំបាកឡើយ ចូរយកព្រែសមកចងរិតកឲ្យស្លាប់តាមប្រក្រតីចុះ ។ ចូធូក៏ឲ្យយកព្រែសមកធ្វើតាមពាក្យនាងថា ។ ព្រះចៅហៀនតេក៏ទ្រង់ព្រះកន្សែងសោកាហើយត្រាស់នឹងនាងតាំងគុយហ៊ុយថា ខ្លួននាងនឹងស្លាប់ទៅហើយក៏កុំបីមានកំហឹងនឹងគុំគួននឹងយើងឡើយ ។ ព្រះចៅហៀនតេនឹងព្រះនាងហុកហៅនាងតាំងគុយហ៊ុយសោកាពិលាប អាឡោះអាល័យគ្នាទៅវិញទៅមក ។ ចូធូឃើញដូច្នោះក៏ស្រែកគំហកថា " គប់គិតគ្នានឹងធ្វើប្រ-ទូសរ៉ាយគេ លុះគេចាប់បានមកធ្វើជាយំយែកអាឡោះអាល័យគ្នា " ហើយចូធូក៏បង្គាប់ពេជ្ឈឃាដឲ្យឃុំនាំខ្លួននាងតាំងគុយហ៊ុយ ចេញទៅ

ដល់ក្រៅទ្វារព្រះបរមរាជវាំង ឲ្យយកព្រ័ត្រចងរឹតបំពង់កទាល់តែដាច់ខ្យល់ស្លាប់ ។ ចួចបង្គាប់នាហ្មឺនសព្វមុខមន្ត្រីខាងក្រុមវាំងនិងខន្ទីថា " ចាប់តាំងពីត្រឹមនេះតទៅ កុំឲ្យពួកព្រះរាជវង្សចេញចូលទៅមកខាងក្នុងព្រះបរមរាជវាំង បើអ្នកណាចង់ចូលចេញឲ្យយកសេចក្តីប្តឹងយើងជាមុន បើយើងយល់ព្រមទើបចេញចូលបាន បើម្នាក់ណាមិនបាមប្រាមដូច្នេះទេ យើងនឹងឲ្យចុះទោសប្រហារជីវិត " ហើយបង្គាប់ទាហានឲ្យប្រជុំទាហាន ៣ ពាន់ កាន់កាប់រក្សាព្រះបរមរាជវាំងនិងទ្វារ កុំឲ្យព្រះរាជវង្សចូលទៅខាងក្នុងបាន ។

ចួចក៏ចេញមកផ្ទះហើយប្រឹក្សានឹងធៀយ៉ុកថា តាំងស៊ុននឹងពួក ៤ នាក់ដែលគិតប្រទូសរ៉ាយយើងនោះ យើងក៏សម្លាប់ចេញអស់ហើយ នៅតែឡៅពីនឹងម៉ាថេង យើងនឹងគិតធ្វើប្រការម្តេច ទើបនឹងបានខ្លួនមកសម្លាប់ចេញ? ។ ធៀយ៉ុកឆ្លើយថា ម៉ាថេងដែលទៅនៅស្រុកសែលៀងនោះមានទាហានច្រើនណាស់ បើលោកនឹងលើកទ័ពទៅវាយយកវេលានេះ ស្រុកយើងក៏ជាកន្លង់ក្រោយ សូមឲ្យលោកចាត់រកអ្នកមានជំរះប្រាជ្ញាទៅបញ្ចុះបញ្ចូលម៉ាថេងឲ្យត្រឡប់ចូលមកស្រុកវិញ កុំឲ្យដឹងខ្លួនទាន់ថាលោកសម្លាប់តាំងស៊ុននឹងគូកននោះឡើយ បើគិតដូច្នេះហើយខ្ញុំបាទយល់ឃើញថា ម៉ាថេងមិនទាន់ដឹងការណ៍ក៏នឹងចូលមកមិនខាន រួចសឹមលោកឲ្យចាប់ខ្លួនសម្លាប់ចេញនឹងបានដោយងាយ ឯឡៅពីនោះទៅនៅស្រុកឈើដីវប្រមូលសេនាទាហាននឹងចាំទទួលកងទ័ពលោក ឥឡូវទាហានអ៊ូនសៀវនឹងទាហានយើងក៏នៅតាំងរាំងរក្សានៅតំបន់គួរត មុខ

ជាឡេតពីនឹងឲ្យមានសំបុត្រទៅគិតនឹងអ្នកសៀវឲ្យជាពួកជាមួយគ្នា បើលោកលើកកងទ័ពទៅច្បាំងនឹងឡេតពីវេលាណា គង់អ្នកសៀវនឹងលើកមកវាយយកក្រុងហ្នឹងតោជាប្រាកដ នរណានឹងតទល់នឹងអ្នកសៀវក៏កម្រក្រៃក្រៃណាស់ ។ ចុចូតបថា ឡេតពីនោះជាមនុស្សមានសតិបញ្ញា បើនឹងបង្អន់ឲ្យយូរការក៏នឹងមានកំឡាំងច្រើនឡើង ឧបមាដូចកូនសត្វបក្សីកំពុងតែដុះក្រាស មិនទាន់មានស្លាបនឹងហើរ បើយើងនឹងស្ងៀមទុកឲ្យនៅក្នុងសម្បុកដូច្នេះ កាលណាដុះរោមនឹងស្លាបព្រមហើយក៏នឹងហើរទៅផ្សាយបាន ទោះនឹងប្រាថ្នាចាប់ខ្លួនក៏កម្រណាស់ អ្នកសៀវនោះមានទាហានច្រើនក៏មែន តែដម្រេះប្រាជ្ញាតិច ទោះនឹងគិតការអ្វី យើងមិនត្រូវខ្លាច ។

(មានត)

## សូមដាស់តឿន :

ក្នុងសម័យនេះ ប្រទេសយើងមានទូតនឹងជនផ្សេងប្រទេស ដែលរាប់អានព្រះពុទ្ធសាសនា ដូចភូមា ខ្មែរ ឥណ្ឌៀជាដើម ចូលមកនៅជាច្រើន, ក្នុង ក្រុងយើង គេមកនៅយូរ ៗ ទៅ គេអាចដឹងសេចក្ដីប្រព្រឹត្តរបស់បព្វជិតយើង បានយ៉ាងជាក់ច្បាស់នឹងភ្នែកគេ កាលបើឃើញបព្វជិតក្នុងសាសនាយើងប្រព្រឹត្តមិនល្អ គេក៏តិះដៀល, បើគេឃើញប្រតិបត្តិល្អ គេក៏នាំទៅសរសើរប្រាប់ក្នុងស្រុកគេ ។

ប្រែចាកទស្សនាវដ្ដីធម្មសាសនាភាសាថៃ

អ្នកប្រែ: ចាប - ពិន

ដំណើរតាមខ្យល់ក្នុងផកាឆ្ការ:

## លោក ផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

គេឃើញពួកបរិស័ទនាំគ្នាដើរដង្ហែទៅក្នុងបូជនីយដ្ឋានមេត ប្រកបដោយចិត្តរីករាយបរិសុទ្ធដូចជាកាលដីដូនដីតាយើងពីដើម នាំគ្នាចេញពីគ្រប់ច្រកល្ហកក្នុងប្រទេសអឺរ៉ុប ដង្ហែគ្នាដើរជើងទទេទៅ កាន់ហ្សេរុយហ្សាឡែមទៅកាន់ក្រុងរេម ដូច្នោះដែរ ។

ហេតុនេះ គឺជាពិធីមួយដ៏អ៊ឹកអធឹក បើកាលណាពួកឯកសិទ្ធិបាន ទៅកាន់ទីមេត ហើយត្រឡប់មកកាន់ភូមិវិញ ។

ក្នុងឱកាសដ៏ឧឡារិកនោះ នៅត្រង់ទីធ្លាមួយយ៉ាងធំ មានប្រជុំអ្នកលេងល្បែងផ្សេងៗ ជាច្រើន រឿងនេះជាលេះដល់ស្រី ប្រុស ចាស់ ក្មេង កំលោះ ក្រមុំ នាំគ្នាទៅស្ដាប់ភ្លេង ស្ដាប់ចម្រៀង មើលគេរាំរែក នឹងលេងល្បែងគ្រប់ជំពូក ដែលត្រូវចំណុចដួងវិញ្ញាណផងមនុស្សប្រុញា-ប្រទេស ព្រោះអ្នកលេងច្រើនតែច្រៀងរាំត្រង់រឿងរពុកស្រុកកំណើត ។

ពេលព្រឹកនោះ បងប្អូនស្រីៗ គុស្តាហ៊ុលសួរនាងឡូឡាដែលហាក់ដូចជាកំពុងស្ងួនចិត្តក្នុងអារម្មណ៍ណាមួយថា:

"ឡូឡា! មិនទៅអណ្ដូងទឹកទេឬព្រឹកនេះ?" ។

នាងក្រមុំញីម៉ាវរួចយកក្រមាទទូរហើយនាំគ្នាទាំងអស់ដើរចេញទៅៗ នាងឡូឡាស្រងូតស្រងាត់ ព្រោះឃើញអ៊ុស្តាអ៊ុលដូចជាមានចិត្តប្រព្រឹត្ត

ទៅក្នុងអារម្មណ៍ដដែល ៗ នាងមិនដឹងបំណងស្រមៃនឹងយោបល់ដែលនាំឲ្យអ៊ីស្មាអ៊ីលព្រួយ ៗ នាងនឹកដោយសេចក្តីស្រងេះស្រងោចម្តងៗ ថា ប្រហែលមានថ្ងៃណាមួយ នាងនឹងត្រូវឃ្លាតចេញពីគេហស្ថានលោកតាអៃយ៉ាដដែលបានចូលសេចក្តីសុខ នឹងត្រូវខានឃើញមុខអ៊ីស្មាអ៊ីលដែលនាងប្រគល់ជូនព្រលឹង ជាគូសេចក្តីស្នេហាដ៏ធំរបស់នាង ៗ កាលណានាងនឹកដូច្នេះឡើង ក៏ហាក់ដូចជាស្មើនឹងរលួយថ្លើមប្រមាត់ ៗ កាលនារីតាំងឡាយទៅដល់ទីប្រជុំ ហើយបានឃើញតាចាស់ម្នាក់ពាក់ក្បាច់ញាក់មុខ ពោះកំប៉ោង គេនាំគ្នាសើច រួចដើរសន្សឹមៗ ហួសទៅកន្លែងអណ្តូងទឹកចាស់មួយដែលតាំងនៅចុងខាងនាយកន្លែងវៀណរគ្គ មានគុម្ពអម្ពិលទឹក នឹងដើមកុលាបដុះព័ទ្ធជុំវិញ ៗ

វេលាដែលនារីដដែលកំពុងទ្រោបធ្វើវ្ហលើមាត់អណ្តូង អាត់តែប្រុងស្តាប់ចម្រៀងដ៏ស្ញូញនៃពួកអ្នកភ្លេង មានស្ត្រីចាស់ម្នាក់ស្លៀកពាក់សាកត្រាក តាមរបៀបប្រទេសអាហ្វ្រិក សក់ខ្មៅរលើប ពាក់រង្វង់ស្ពាន់ពីលើផ្ទះ ដើរចូលមកជិតនាងឡីឡា ៗ

មុនដំបូង ឡីឡាថយក្រោយ តែយាយនោះញញឹមមករកហើយនិយាយថា:

—"កុំខ្លាចអី នាងក្រមុំ យាយឥតមានរកវៀនធ្វើការអាក្រក់អ្វីដល់នាងទេ ៗ នៃមាសពៅ ហេតុអ្វីក៏នាងស្រងូតស្រងាត់អ៊ីម្ល៉េះ? ទុកឲ្យយាយទាយព្រេងវាសនាឲ្យមើល" ៗ

ឡីឡា សំឡឹងយាយមេអាបដោយសេចក្តីងឿងឆ្ងល់ ស្ទើនេះមើល

ចុះដល់ចិត្តខាងក្នុងរបស់នាងជាប្រាកដ ដ្បិតគាត់ថាត្រូវត្រង់នាងព្រួយ ។ ពេលនោះ ឡីឡា ធ្វើអាការប្រែមប្រុំ ចំណែកប្អូនទឹងប្អូនស្រីដ៏ជួនមួយ នៃអ៊ីស្មាអ៊ីលអាល័យតែចាក់ស្រាឲ្យអ្នកប្រេងផឹក ។ នារីទាំងនេះ ប្រហែលនឹងឃាត់នាង ឡីឡា មិនឲ្យទៅតាមយាយមេអាបទេ ប្រសិនបើដឹង ប៉ុដ្បិតស្រី ៗ តែងចូលចិត្តជឿទំនាយ ។

ម្យ៉ាងទៀត នាងឡីឡានឹកថាប្រហែលជានឹងមិនមានគ្រោះថ្នាក់អ្វីទេ នៅកណ្តាលហ្វូងមនុស្សឈូឆរ រួចទើបនាងដើរតាមយាយមេអាបរហូតដល់កៀនកន្លែងមួយតូច ជាប្រកៈនៅខាងក្រោយកំពែងចាស់ពីបុរាណមួយ ទីនោះជាកន្លែងសំណាក់អាស្រ័យសំចតរបស់យាយអាហ្វ្រិក ។ នាងឡីឡាហុចដៃទៅឲ្យយាយចាស់ ៗ ចាប់ដៃ ហើយហាក់ដូចជាសំឡឹងសង្កេតខ្សែដៃយ៉ាងយូរ ទើបទាយថា:

– " នាងឯងនឹងមានគូស្នេហ៍ព្រមទាំងសេចក្តីសុខដ៏ប្រសើរ ។ កុំខ្លាច អ្នកនោះស្រឡាញ់នាងណាស់ ។ មានថ្ងៃណាមួយ គេនឹងនាំនាងឯងចេញទៅនៅទីដទៃ ឆ្ងាយពីស្រុកនេះ" ។

សំដីផងយាយអាបបំពេញចិត្តនាងក្រមុំដោយសេចក្តីសប្បាយ ។ ក្នុងទំនាយនោះ នាងចូលចិត្តថាប្រាកដជានិយាយពីអ៊ីស្មាអ៊ីលហើយ ព្រោះនាងចង់ឲ្យការណ៍ដែលនាងប្រាថ្នាសម្រេចតាមបំណង ។

យាយអាហ្វ្រិក ស្ទង់សំដីទៅប្រហែលជាបានការ ក៏និយាយថែមទៀតថា:

" ល្ងាចនេះ ពេលយប់ស្ងាត់គេដេកអស់ ចូរនាងមកចាំក្បែរ

អណ្តូងនេះកុំខាន ។ គូស្នេហារបស់នាងនឹងមកជួប ហើយនឹងនិយាយប្រាប់សេចក្តីប្រតិព័ទ្ធរបស់គេដល់នាង កុំភ័យបារម្ភអ្វី ឥតមាននមនុស្សក្នុងផ្ទះណាគន់មើលឡើយ” ។

សំដីខាងក្រោយនេះ រិតតែបញ្ជាក់គំនិតនាងឡូឡាឲ្យសន្និដ្ឋានថា ប្រាកដជាអស្ចារ្យពិតហើយ ។ លុះនាងឡូឡាត្រឡប់មកជួបនឹងនារីជាគូកនវិញ នាងទាំងនេះឆ្ងល់ពេក ដោយឃើញឡូឡារីករាយស្រស់ប៉ប្រែ ។ គេចូលចិត្តឥតសង្ស័យថាប្រាកដជាពិធីនេះហើយ ដែលធ្វើឲ្យឡូឡាមានទឹកមុខស្រស់សប្បាយ ។ នារីទាំងឡាយក៏ត្រឡប់វិលចូលទៅកាន់ទីលំនៅដោយអស់សំណើចរៀងខ្លួន អំពីរឿងផ្សេងៗ កើតមានក្នុងពិធីបុណ្យដែលបានឃើញ ។

ខណៈនោះ គ្រាន់តែនាងឡូឡាចេញផុតភ្លាម យាយមេអាបលបចូលទៅខាងក្រោយគុម្ពកូឡាប ដែលសៀមពួននោះ គេងើបឡើងហើយសួរថា:

– “ដូចម្តេចទៅ ?” ។

យាយអាបឆ្លើយថា:

– “ឱព្រះតេជៈគុណអើយ នាងនេះស្លូតដូចកូនពពែទើបនឹងកើត ហើយខ្ញុំបានប្រាប់ឲ្យនាងមកត្រង់អណ្តូងទឹកក្នុងយប់នេះ” ។

សេចក្តីសប្បាយរីករាយចាំងរស្មីចេញតាមភ្នែកសៀម ។ ស្រែកហើយបោះប្រាក់មួយស្បោងពេញទៅឲ្យយាយអាបថា:

– “ហ៎ ! លោកយាយ អញ្ជើញយកចុះ !” ។

យាយអាបអាត់តែឱនស្រវារើសប្រាក់ រស្មីរត់ថយចេញជាប្រញាប់ដើរដំហានវែងៗទៅឆ្ងាយបាត់ ។ យាយអាបឱនក្បាលដល់ដី ហើយស្រែកឲ្យពរថា:

— “សូមព្រះអាឡ្យស់រក្សាអ្នក ! សូមព្រះអាឡ្យស់ស្ថិតនៅក្នុងខ្លួនអ្នក ! សូមព្រះអាឡ្យស់ប្រសិទ្ធិឲ្យអ្នកមានអាយុយឺនយូរ !” ។

យាយអាបស្រែកឲ្យពរទាល់តែមើលរស្មីលែងឃើញ អ្នកកំលោះដើរបត់តាមផ្លូវកែងទៅបាត់ ។

យាយអាប ទោះបំណាស់ប៉ុណ្ណឹងហើយ ក៏អាចស្ទុះក្រោកឡើងបានភ្លាមដើរប្រញេបប្រញាប់ ចូលតាមផ្លូវមួយតូចនៅប៉ែកខាងទិសផ្ទុយគ្នានឹងផ្លូវដែលរស្មីដើរទៅ ។ យាយអាបដើរមិនបង្អង់រហូតដល់ទ្វារក្រុង ហើយគេចចូលក្នុងតៀមមួយនៅក្បែរវាលខ្សាច់ មានលក់គ្រឿងស៊ីផឹកគ្រប់យ៉ាងគឺ នំផ្អែម កាះហ្វ ទឹកឪឡឹក ទឹកស៊ីរ៉ូ ។

នៅត្រង់ត្រលៀតតៀមនោះ មានមនុស្សប្រុសម្នាក់អង្គុយលើស្បែកចៀមកំពុងបឺតបារី ។ មានឈ្នួលម្នាក់ស្លៀកខោខ្លី ស្រោមជើងស្បែក ពណ៌ស៊ីជម្ពូក្បាលពាក់ក្រពះ អង្គុយងោកភ្ញុកលើកន្ទេលមួយ ។

កាលដែលយាយចាស់ចូលទៅ អ្នកបំរើនេះក៏មិនកំរើកខ្លួន ។ យាយអាក្រឡេកចាំបានទូវមនុស្សដែលគាត់មករក គឺអ្នកដែលកំពុងជក់បារីនោះឯង ។ អ្នកនេះងើបក្បាល ហើយធ្វើសញ្ញាឲ្យយាយចាស់ចូលមក ។ គាត់ចូលមកជិតអង្គុយលើស្បែកចៀមជាមួយគាឡប ហើយក៏រ៉ាយរ៉ាប់ប្រាប់ទូវកិច្ចដែលទើបនឹងកន្លងទៅហើយ និងនាងឡូឡាដែល

ត្រូវមកត្រង់កន្លែងអណ្ដូង វេលាយប់នេះដើម្បីជួបនឹងសៀម ។ គាត់និយាយយ៉ាងតិចៗ ដោយក្បត់ការទំនុកទុកចិត្តនៃបេនអាប់ដាឡះ ព្រោះគាត់បានរង្វាន់សុទ្ធតែប្រាក់ ចំណែកគាត់ទើបបានសុទ្ធតែមាសមួយស្បោងពេញៗ ធម្មតាជាតិស្ត្រី យាយអាបក៏ដូចស្ត្រីទាំងឡាយដទៃដែរ តែងត្រូវការមាសប្រាក់ពន់ពេក កម្រជាអ្នកសន្ដោសណាស់ឡើយ ។

*
* *

ពេលរសៀលនេះ លោកតាអៃយ៉ាដ អាក់ខានពុំបានអានធម៌ (គួរ៉ង់) ដែលលោកត្រូវមើលរាល់ថ្ងៃ ព្រោះលោក មូហាម្មដ ណា-ប៊ីបី ជាវរសេនីយត្រីនៃកងទ័ពតូចនៅកាសិ-កាកប៊ូល៍ ត្រូវការចង់ជួប ។

លោកវរសេនីយ៍នេះអញ្ជើញមក មានពួកនាយទាហានជាច្រើនជូនមកផង ដើម្បីជួបសន្ទនាការនឹងលោកតា កាអ៊ីត ហើយនឹងចង់ដឹងឲ្យច្បាស់នូវដំណើររដ្ឋាភិបាលនៃកុងស្តង់ដីណុប ដែលអាចពឹងលើសេចក្ដីស្មោះស្ម័គ្រនឹងការយកចិត្តទុកដាក់នៃមេកូម៉ិនេះ ដែលមានអានុភាពដ៏ធំក្នុងតំបន់ តើបែបណា ?

មុក្ដារមកឲ្យដំណឹងដល់អ៊ីស្មាអ៊ីលថា :

— “លោកឪពុកមានប្រសាសន៍ហៅបង ដើម្បីចេញទៅទទួលជាកិត្តិយសផ្ទះ នូវពួកនាយទាហានតួរគីដែលមកចង់ជួបនឹងលោក” ។

អ៊ីស្មាអ៊ីលព្រមទៅទាំងទើសទាល់ ។

គេមិនមែនមិនសប្បាយនឹងលោកឪពុកទេ តែគេមិនចូលចិត្តនឹងពួកតួរគី ។ គេដឹងថាគេមិនចូលចិត្តជាច្រើននឹងប្រជាជនតួរគី គឺជាសាសន៍

មិនសុចរិត ច្រើនវៃឆ្លយន់ឃ្លង មិនសុខុមៈស្នេហាណាមួយដែលសំដែងឲ្យឃើញចំពោះជាតិអ៊ីតាលីដែលជាអ្នកលុកលុយសង្កត់សង្កិនដូចគ្នា ។ អ៊ីស្មាអ៊ីលមានបំណងថា សាសន៍អាក៉ប់ត្រូវនៅជាអព្យាក្រឹត្យ ក្នុងសង្គ្រាមរវាងប្រជាជនទាំងពីរ ។

ម្យ៉ាងទៀត អព្យាកតភាពនេះ គឺជាលក្ខន្តិកៈមួយដែលគេបានស្នើទុកក្នុងកិច្ចសញ្ញាចុះចូលដែលអាក៉ប់ទាំងឡាយបានសម្រេចនៅចំពោះមុខនៃពួកតួរគីហើយ ។

ពេលនោះ អ៊ីស្មាអ៊ីល ខំអត់ទ្រាំទៅសំដែងមុខនៅក្បែរលោកឧតុកក្នុងសាលកិត្តិយស ហើយតាមទំនៀមស្រុក គេត្រូវឱនគំនាប់នាយទា-ហានតួរគី ម្នាក់បីដង ។

លោកមូហាម្មេដ ណាប៊ីប៊ី ចូលក្នុងបន្ទប់ទទួលភ្ញៀវបន្ទាប់លោកតាអៃយ៉ាជ ។ ពួកអ្នកបំរើលើកទឹកតែក្រអូប ផ្លែទំពាំងជូរពណ៌ក្រមៅមានរសផ្អែម ប៉ុនៗផ្លែតុទ្រា ដាក់លើថាសប្រាក់ នាំមកជូនគ្រប់គ្នា ។

កាលណាកិច្ចគួរសមចំពោះគ្នាទៅវិញទៅមកធ្វើរួចហើយ លោកមូ-ហាម្មេដណាប៊ីប៊ី ជានាយទាហានចាស់ជាងគេ ជាមនុស្សម៉ាំងទាំងប្រើតែអំណាច យកតែសិទ្ធិនៃអ្នកមានកំឡាំងមកប្រើ ហានិយាយផាំងថា:

– “អញប្រាប់ឯងឲ្យដឹង: រស៊ីម បេន អាប់ជាឡះចូលដៃជាមួយនឹងយើងហើយ គេធ្វើជានាយត្រួតទាហាននៅក្រុងកាស៊ុ - កាកប៊ូលី ឥឡូវគេកំពុងរៀបចំកន្ទ្វែងចាំស្ទាក់បាញ់ពួកទ្ហល” ។

អ៊ីស្មាអ៊ីលស្រែកឡើងថា:

— "ធ្វើបែបនេះ ជាការក្បត់!" ។

លោកមូហាម្មេដណាប៊ី បែរមុខចំអ៊ីស្មាអ៊ីល ហើយសួរថា:

— "ចូរឯងប្រាប់យើងមកមើល តើហេតុដូចម្តេច?" ។

អ៊ីស្មាអ៊ីលឆ្លើយប្រាប់ថា:

— "ខ្ញុំដូចជាចាំថា: ក្នុងសញ្ញាចុះចូលរបស់យើង មាននិយាយអំពីអព្យាកតភាពក្នុងនោះវិញទេ ពេលណាបើមានជំលោះកើតឡើងរវាងរដ្ឋាភិបាលរបស់លោកនឹងរដ្ឋាភិបាលនៃជនបរទេស" ។

នាយទាហានតួរគីសើចចំអក សំដែងទឹកមុខម៉ឺងម៉ាត់ រួចតាំងនិយាយដោយសំដីច្បាស់ៗថា:

— "ចូរឯងដឹងច្បាស់ថា អព្យាកតភាព គេចុះឲ្យតែមាននៅលើក្រដាសប៉ុណ្ណោះទេ ។ គឺជាសំដីដែលអ្នកនិយាយការណ៍ចេះតែប្រឌិតឲ្យតែមានឡើង!

"នែ អ៊ីស្មាអ៊ីល បេន អៃយ៉ាដ ឯងត្រូវដឹងថា ក្នុងពេលមានជំលោះគេចាប់មិត្តភក្តិដែលនៅជាមួយបញ្ចូលឲ្យជួយផងហើយ អ្នកណាមិនចូលជាមួយនឹងយើងៗ យើងទុកអ្នកនោះជាសត្រូវនឹងយើង, ហ្នឹងហើយគឺជាច្បាប់ចម្បាំង!

សៀមបានបង្ហាញសេចក្តីក្លាហាននឹងចិត្តស្មោះសរឲ្យយើងឃើញហើយ ។ យើងសង្ឃឹមថាដល់វេនឯងៗនឹងទៅជាមួយនឹងយើងមិនខាន!" ។

អ៊ីស្មាអ៊ីលបែបចង់មិនយល់ព្រម តែលុះសំឡឹងទៅទឹកមុខឪពុកគេ ក៏ឈប់ស្ងៀមទៅវិញ ។

លោកតា កាអ៊ុត នៅស្ងៀមឈឹង, ការស្ងៀមនេះជាអាវុធមួយដ៏គួរភ័យនៃជាតិអ្នកប្លន់ប្រទេស, តែក្នុងលោកអន្ទរកូន ប្រាប់ថាត្រូវប្រយ័ត្ន, ទើបអ្នកកំលោះបែរមករកនាយទាហានហើយឱនគំនាប់ឲ្យសញ្ញាថាយល់ព្រមតាម ។

*

*   *

នៅឱកាសជាមួយគ្នា ក្នុងភូមិដែលរស្រីមបេនអាប់ដាឡេះនៅ ក្នុងសង្កាត់នោះបរិបូណ៌ដោយផ្ទះលក់ទំនិញ មានមនុស្សម្នាក់មកសួររកបង់ប្អូនទឹងមេសង្កាត់ ។

រស្រីមបង្គាប់ថា:

– ត្រូវឲ្យគេចូលមក !

លុះភ្ញៀវចូលដល់ រស្រីមសួរថា:

– តាឡិប គ្មានរឿងអ្វីប្លែកទេឬ?

– គ្មានទេ ចៅហ្វាយ ! ប៉ុន្តែយប់នេះ ខ្ញុំនឹងនាំនាងឡឺឡាមកជូន !

រស្រីមញញឹម ៗ ដោយនឹកថាបំណងរបស់ខ្លួននឹងសម្រេច ។

– ល្អហើយឯងត្រូវនាំវាទៅឯអណ្តូង អញនឹងឲ្យរង្វាន់ដល់ឯងទៀត !

*

*   *

(មានត)

# រឿងបល្ល័ង្កទិព្វ សាមសិបពីររឿង

រឿងព្រេងនិទាន

## លោកសមិន មូត្យេនជមៈ តែង

## លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទីប្រាំ

ព្រះមហាក្សត្រភោជៈ ទ្រង់សម្រេចក្នុងព្រះទ័យថា នឹងប្រកាសឲ្យធ្វើរាជាភិសេកទ្រង់ឲ្យសោយរាជ្យជាស្ដេចពេញលក្ខណៈ ទ្រង់ស្ដេចទៅកាន់បល្ល័ង្កទិព្វដោយមានព្រះរាជទីប្រឹក្សាជាបរិវារហែហមផង ៗ លុះទ្រង់យាងទៅជិតបល្ល័ង្កនោះ រូបទេពនិម្មិតទីប្រាំក្រាបទូលថា "បពិត្រព្រះមហាក្សត្រភោជៈ សូមទ្រង់ព្រះសណ្ដាប់ទូលបង្គំ ព្រះមហាក្សត្រអង្គណា ដែលនឹងគង់នូវលើរាជបល្ល័ង្កព្រះបាទវិក្រមទិត្យបាន លុះត្រាតែមហាក្សត្រអង្គនោះមានព្រះទ័យសប្បុរសដូចព្រះបាទវិក្រមទិត្យ" ៗ ព្រះមហាក្សត្រភោជៈ ទ្រង់មានបន្ទូលសួរទៅរូបទេពនិម្មិតនោះថា "ព្រះទ័យសប្បុរសនៃព្រះបាទវិក្រមទិត្យយ៉ាងណាទៅ?" ៗ រូបទេពនិម្មិតទីប្រាំក្រាបទូលថា "បពិត្រមហារាជ! សូមមហារាជទ្រង់ព្រះសណ្ដាប់ចុះ"។ ៗ

នៅក្នុងទីក្រុងអវន្តី ព្រះបាទវិក្រមទិត្យទ្រង់គង់នៅលើរាជបល្ល័ង្កកណ្ដាលព្រះរាជទីប្រឹក្សា ទ្រង់កំពុងចាត់ការផ្សេងៗ ក្នុងព្រះរាជអាណា-

បក្រ, ក្នុងពេលនោះនាយខ្មៅព្រានបាលបានចូលមកដល់ទ្វារព្រះរាជមន្ទីរ ហើយពោលទៅកាន់នាយទ្វារបាលថា "ត្រូវតែខ្ញុំចូលទៅគាល់ព្រះមហាក្សត្រ, អ្នកចូរក្រាបបង្គំទូលព្រះមហាក្សត្រឲ្យខ្ញុំផង" ។ ក្នុងពេលនោះនាយទ្វារបាលក៏ចូលមកថ្វាយដំណឹងនេះចំពោះព្រះមហាក្សត្រ ហើយក៏នាំនាយខ្មៅព្រានបាលចូលទៅ ។ នាយខ្មៅព្រានបាលបានយកដៃទាំងពីរលើកត្រឹមក្បាលថ្វាយបង្គំព្រះមហាក្សត្រ ហើយក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំសូមថ្វាយនូវដំណឹងមួយចំពោះទ្រង់ គឺសព្វថ្ងៃដើមស្វាយ ដូង ស្លា ក្រូចឆ្មារ ក្រូចពោធិសាត់ ចម្បកៈ អសោកៈ កិមសុកៈ ម្ទេះ គោត គមាលៈ សាលៈ បយាលៈ កទលិ កក្កុលៈ លពន្ធ ក្រវាញ កតលី កុន្ទៈ ទមនកៈ សរុបគឺរុក្ខាទាំងអស់ដែលដុះនៅក្នុងព្រះរាជខ្មៅព្រានកំពុងមានត្រួយខ្ចី ផ្កា ផ្លែ គឺពេលគួរព្រះអង្គទ្រង់យាងទៅក្រសាល ក្នុងព្រះរាជខ្មៅព្រាននេះ" ។

ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់នូវសេចក្ដីក្រាបបង្គំទូលរបស់នាយខ្មៅព្រានបាល ទ្រង់ក៏យាងទៅទីនោះ មានក្រុមព្រះពន្ធី (ស្នំ) ព្រមទាំងតាសាទាសីនិងនាងនាដកាជាច្រើនហែហមជាព្រះរាជបរិវារ ។ លុះទ្រង់យាងទៅដល់ព្រះរាជខ្មៅព្រាន ហេតុតែទ្រង់ប៉ុនប្រសប់ខាងចុម្ពិតនាការ (ឱប ថើប) ព្រះសម្រួលនឹងរបាំ ព្រមទាំងទ្រង់ព្រះតស្រ្តដំណើតតាមល្បែងផ្សេង ៗ ការប្រឡែងលេង និងអាកប្បកិរិយាប្លែក ៗ ក៏យាងទៅជាមួយពួកស្រីស្នំដែលមានរូបតោមលោមពណ៌ស្រស់បំព្រង បេះបុប្ផា ឬក្រសាលក្នុងគង្គាឬបេ្រង ឬ គង់លើ (អង្រឹង) ឬយាងទៅពួនក្នុង

គុម្ពោតបុប្ផកខលី ឬបំពេញបំណងនៃស្រីស្នំទាំងនោះ ។ នេះហើយដែលព្រះមហាក្សត្រវិក្រមទិត្យ ទ្រង់ក្រសាលលេងសប្បាយដោយព្រះរាជតម្រេកជាលោកិយក្នុងវេរកាល ។

ក្នុងគ្រានោះ មានតាបសម្នាក់បានបំពេញអត្តកិលមថានុយោគ (គឺការធ្វើខ្លួនឲ្យលំបាក) ជាយូរណាស់មកហើយ បានមកទស្សនានូវព្រះរាជ-ឧទ្យានដែរ ។ ដល់គាត់មើលក្នុងទីនោះ តាបសក៏មានគំនិតប្រែប្រួល ។ ព្រះមហាក្សត្រទ្រង់ត្រាស់សួរថា (ឱយោគី! ដោយហេតុអ្វីបានជាអ្នកចូលមករកយើងក្នុងទីនេះ? ។ យោគីនោះក្រាបបង្គំទូលថា "បពិត្រមហារាជ! ទូលបង្គំបានប្រព្រឹត្តធ្វើបាបរូបកាយនេះនៅក្នុងពេលអស់កាលយូរហើយ ។ ឥឡូវនេះ អាទិទេពដែលទូលបង្គំបួងសួង បានអនុគ្រោះទូលបង្គំជាយ៉ាងក្រៃលែង ហើយបង្គាប់ទូលបង្គំថា "ចូរឯងទៅគាល់ព្រះបាទវិក្រមទិត្យចុះ, ទ្រង់នឹងបំពេញនូវសេចក្តីប្រាថ្នារបស់ឯងមិនខាន" ព្រោះហេតុដូច្នេះ បានជាទូលបង្គំចូលមកគាល់ព្រះអង្គ" ។

ព្រះបាទវិក្រមទិត្យ ទ្រង់ព្រះសណ្តាប់នូវស័ព្ទពចាយោគីនោះហើយ ទ្រង់មានព្រះតំរិះថា "យោគីនេះ, ដោយមិនបានយល់ច្បាស់លាស់នូវន័យសាស្ត្រ ក៏លះបង់ចោលសមាធិកម្មដ្ឋាន, យោគីនេះ នៅជាអ្នកមានទុក្ខក្នុងខ្លួន មានតណ្ហាប្រាថ្នាចង់បានសប្បាយក្នុងកិលេសកាម បើយោគីនេះ មានទុក្ខមែន ត្រូវអញបំពេញនូវបំណងនៃអ្នកដែលមានទុក្ខ" ដល់ទ្រង់ព្រះតំរិះយ៉ាងដូចនេះ ទ្រង់ក៏សម្រេចក្នុងព្រះទ័យថា "នៅកណ្តាលទីក្រុង ទ្រង់នឹងត្រាស់បង្គាប់ឲ្យគេសង់គេហដ្ឋានដ៏វិចិត្រ" លុះ

ជាន់សង់ហើយ ទ្រង់ព្រះរាជទានទៅយោគីនោះ ។ ទ្រង់បានព្រះរាជទាននូវកញ្ញាមួយរូបឆាត់ដែលមានពាក់គ្រឿងអលង្ការគ្រប់យ៉ាង, ភូមិមួយរយ, គោគទ្រព្យជាច្រើន, ទាសាទីទាសី, គោញី, ក្របី, ដំរី, សេះ ។ល។ ដល់សម្រេចកិច្ចហើយ ព្រះអង្គទ្រង់សុពណ៌បាទ មានឫទ្ធានុភាព ទ្រង់ហោះទៅលើអាកាស ចូលទៅក្នុងព្រះរាជធានី លឿនដូចព្រះពាយ ។ ចំណែកឯយោគីនោះ ក៏ត្រេកត្រអាលតាមចិត្តបំណងគ្រប់បែបគ្រប់យ៉ាង នៅក្នុងទីនោះ ។

រូបទេពនិម្មិតទីប្រាំ បានក្រាបបង្គំទូលមហារាជភោជ:ថា “បពិត្រមហារាជ! បើទ្រង់មានព្រះទ័យសប្បុរសស្មើនឹងព្រះបាទវិក្រមទិត្យ, ទ្រង់អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន” ។

ក្នុងពេលនោះ, ព្រះមហាក្សត្រភោជ: ក៏ទ្រង់យាងចេញអំពីទីនោះទៅ ។

* * *

## និទាននៃរូបនិម្មិតទីប្រាំមួយ

ព្រះមហារាជភោជ: ទ្រង់បានសម្រេចព្រះរាជហឫទ័យម្តងទៀតថា នឹងបាត់ឲ្យគេធ្វើមុទ្ធាភិសេកទ្រង់ឲ្យសោយរាជ្យពេញលក្ខណ: ទ្រង់ក៏យាងតម្រង់ទៅកាន់បល្ល័ង្កទិព្វនោះ ។ ក្នុងពេលនោះ រូបទេពនិម្មិតទី ៦ សើចហើយក្រាបបង្គំទូលថា: “បពិត្រព្រះមហារាជ សូមទ្រង់ជ្រាប: អ្នកណាមួយបានធ្វើសប្បុរសធម៌ជួយបុគ្គលដទៃ ដូចព្រះបាទវិក្រមទិត្យ អ្នកនោះទើបអង្គុយនៅលើបល្ល័ង្កនេះបាន” ។ ព្រះមហារាជភោជ:

ទ្រង់មានបន្ទូលសួរថា "ក្រុះការជួយឧបត្ថម្ភអ្នកដទៃនៃព្រះបាទវិក្រមទិត្យនោះយ៉ាងណា.ទៅ?" ។ រូបទេពនិមិត្តទីប្រាំមួយនោះក្រាបបង្គំទូលថា "សូមទ្រង់សូមយកវីរភាពមកជាមូលដ្ឋានក្នុងកិច្ចការដែលទ្រង់ព្រះតម្រិះ ព្រះបាទវិក្រមទិត្យទ្រង់សោយរាជ្យសម្បត្តិ នៅទីក្រុងអវន្តី ទ្រង់បានត្រួតត្រាប្រទេសឯទៀតជាច្រើន ។ ប្រជារាស្ត្រដែលនៅក្នុងភូមិភាគនៃអធិប្រទេសរបស់ព្រះអង្គ បានប្រតិបត្តិនូវករណីយកិច្ចតាមវណ្ណៈគ្រប់ៗគ្នា មិនដែលប្រមាទសោះឡើយ, ពួកនេះបានប្រព្រឹត្តតាមច្បាប់នៃសាស្ត្រ, លះបង់នូវអំពើទុច្ចរិត ព្យាយាមតែជួយគ្នាទៅវិញទៅមក ។ នៅអវសាននៃជីវភាព, អ្នកទាំងអស់នេះ មិនបានស្តាប់នូវស័ព្ទហៅថា ពាក្យភូតកុហក គឺបដិសេធជាអហង្ការ មិនជឿនូវជីវភាពអនាគត ហើយដោយយល់រូបកាយនេះ មិនអាចស្ថិតស្ថេរនៅយូរប៉ុន្មាន, ក៏ពិចារណាជានិរន្តរ៍នូវវិធីបួមព្យាបាយ ដែលទៅកាន់ព្រលឹងធំ គឺព្រះអាទិទេព ។

នៅក្នុងទីក្រុងនោះ មាននាយពាណិជម្នាក់ឈ្មោះ ធនទត្ត (Dhanadatta) ។ ធនទត្តនេះ ជាសេដ្ឋីមានភោគទ្រព្យជាច្រើនអស្ចារ្យ សូម្បីតែខ្លួនគាត់ក៏មិនដឹងនូវចំនួននៃភោគទ្រព្យនោះឡើយ , ហើយគាត់មានវត្ថុជាច្រើនបែប, វត្ថុណាដែលគ្មាននៅទីក្រុងឯទៀត គាត់មានទាំងអស់ ។ មានមួយថ្ងៃ ធនទត្តគិតថា "ការធ្វើអំពើល្អសម្រាប់យកទៅប្រើប្រាស់ក្នុងបរលោក បើអញគ្មានព្យាយាមរកនូវគុណធម៌ទាំងនេះទេ តើជោគវាសនាអញក្នុងកាលជាអនាគតយ៉ាងណាទៅ?" ។ គំនិតនេះគាត់បានកំណត់ក្នុងចិត្តគាត់ស្រេច, គាត់ក៏ចំណាយភោគទ្រព្យ

នោះ បែកទៅជាមានដោយចិត្តសប្បុរសជាយ៉ាងក្រៃលែង, រួចគាត់ក៏អញ្ជើញទៅទស្សនានូវស្រះពិសិដ្ឋ ។ ដល់គាត់មើលលេងកំសាន្តនូវស្រះពិសិដ្ឋទាំងនោះ, គាត់ទៅដល់កោះមួយនៅក្នុងសមុទ្រ ។ នៅទីនោះ មានបូជនិយដ្ឋាននៃអាទិទេពមួយនៅជិតបូជនិយដ្ឋាននោះ មានបឹងមួយ, ហើយនៅទិសទាំងបួននៃបឹងនោះមានតិរវ៉ី(១)មួយ ក្រាលសុទ្ធតែត្បូងទឹងចក្រៃ ។ គាត់បានឃើញនៅទីនោះ នូវស្ត្រីម្នាក់មានរូបឆោមលោមពណ៌ស្អាតអស្ចារ្យ និងបុរសម្នាក់ល្អដូចទេវតា, តែក្បាលអ្នកទាំងពីរគេកាត់ដាច់; ក្បាលនេះស្ថិតនៅដោយឡែក, ហើយនៅជិតក្បាលនោះមានថ្មមួយ(២) ដែលគេចារឹកអក្សរទុកថា "បើបុគ្គលណាមានចិត្តសប្បុរស កាត់ក្បាលខ្លួនបូជាទៅអាទិទេព មនុស្សប្រុស-ស្រីទាំងពីរនោះអាចមានជីវិតឡើងវិញបាន" ។ ធនទត្ត បានឃើញនូវរឿងរ៉ាវប្លែកអស្ចារ្យដូចនេះ ក៏ចេញពីបឹងនោះវិលត្រឡប់មកកាន់គេហដ្ឋានវិញ ។

មានមួយថ្ងៃ, ក្នុងកិច្ចសន្ទនាការជាមួយព្រះមហាក្សត្រ ធនទត្តបានក្រាបបង្គំទូលព្រះអង្គនូវរឿងរ៉ាវខាងលើសព្វគ្រប់ ។ ព្រះអង្គទ្រង់ព្រះសណ្ដាប់នូវសំដីពាក្យនៃធនទត្ត , ទ្រង់មានព្រះទ័យឆ្ងល់ពន់ពេក ហើយមានព្រះបន្ទូលថា "ធនទត្ត, អ្នកទៅជាមួយនឹងយើងកាន់ទីនោះ យើងចង់ឃើញរបស់ប្លែកនោះយ៉ាងណាទៅ?" ។ ព្រះមហាក្សត្រិយ៍

---

១ តិរវ៉ី គឺផ្លូវក្បែរមាត់ច្រាំងនៃបឹងនោះ ។ ២ ទម្លាប់សរសេរនៅលើថ្មនេះ គឺពិត ព្រោះគេបានឃើញសិលាចារឹកមានជាច្រើនកន្លែងប្រហែលជា ៩០ ឆ្នាំមកហើយ, មិនមែនមានតែប្រទេសឥណ្ឌានោះទេ ប្រទេសណាក៏មានដែរ ។

ទ្រង់សម្រេចដោយព្រះអង្គឯងដូចនេះ ទ្រង់ក៏យាងទៅជាមួយនឹងធនទត្ត កាន់ទីនោះ ។ ដល់ទ្រង់យាងទៅដល់, ទ្រង់បានទតយល់រឿងរ៉ាវដូចជា ធនទត្ត បានក្រាបទូលទ្រង់ពីមុន ។ រួចទ្រង់ព្រះតម្រិះដូចនេះថា “អ្នកដែលគេទុកជាឧត្តមបុរស តែងលះបង់ជីវិតរបស់ខ្លួន ដើម្បីប្រយោជន៍អ្នកដទៃ, បើអញបូជាជីវិតអញ, រូបនៃបុគ្គលទាំងពីរទាំងបុរសស្ត្រី នឹងមានជីវិតរស់នៅឡើងវិញ នេះជាសកម្មភាពដ៏ឧត្តម; ត្រូវតែប្រព្រឹត្តបែបនេះជាដាច់ខាត, បើទុកជាគេថ្នាក់ថ្នមរូបយ៉ាងណា គេក៏មិនអាចរួចផុតពីសេចក្តីស្លាប់, បើគេធ្វើការដើម្បីប្រយោជន៍អ្នកដទៃ គេអាចទទួលមរណភាព តែដល់ទៅក្នុងបរលោក គេបានជាគាប់សនាដ៏ប្រសើរ” ។

ព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះចិន្តាដូចនេះ ទ្រង់យាងទៅស្រង់ព្រះខគ: ក្នុងបឹងនោះ រួចទ្រង់លើកព្រះខ័នថា ដើម្បីនឹងកាត់ព្រះសិរព្រះអង្គ, តែក្នុងពេលនោះអាទិទេព បានចាប់ព្រះហស្តព្រះអង្គទុក ហើយក្រាបទូលថា “ឱមហារាជ ព្រះអង្គជាឧត្តមបុគ្គល ទូលបង្គំសប្បាយចិត្តនឹងទ្រង់ពន់ពេក ។ ចូរមហារាជមានព្រះរាជបំណងចង់សូមអ្វីពីទូលបង្គំ ៗ នឹងធ្វើឲ្យសម្រេចបាន” ។ ព្រះមហាក្សត្រទ្រង់មានបន្ទូលតបទៅនឹងអាទិទេពវិញថា “ឱអាទិទេព, បើព្រះអង្គចង់អនុគ្រោះចំពោះយើង, សូមឲ្យព្រះអង្គធ្វើឲ្យមនុស្សទាំងពីរនាក់ ទាំងបុរសស្ត្រីឲ្យមានជីវិតឡើង ហើយប្រគល់រាជបល្ល័ង្កឲ្យអ្នកទាំងពីរសោយរាជ្យជាស្តេចនៅទីនេះ ។ អាទិទេពទ្រង់ព្រះសណ្តាប់នូវមហារាជមានព្រះឱង្ការដូចនេះ ទ្រង់ក៏ក្រាបទូល

ថា ឱមហារាជវិក្រមាទិត្យ ទ្រង់ជាមហាបុរស, ដើម្បីនឹងធ្វើប្រយោជន៍ចំពោះជនដទៃ ទ្រង់គិតនឹងធ្វើពលិកម្មនូវជីវិតទ្រង់” ។ ហើយអាទិទេពនោះក៏ធ្វើឲ្យមនុស្សទាំងពីរនាក់ទាំងបុរសនិងស្ត្រីឲ្យមានជីវិតរស់ឡើងវិញ ហើយប្រគល់រាជសម្បត្តិឲ្យសោយនៅទីនោះ រួចក៏បាត់ពីទីនោះទៅ ។ ដោយសេចក្ដីអនុគ្រោះនៃអាទិទេព មនុស្សប្រុស-ស្រីនោះ ដូចជាមនុស្សដេកលក់ក្រោកឡើងដោយមានគេទៅដាស់ក្រោកឡើង ។ ត្រឡប់ទៅជាព្រះមហាក្សត្រ និងព្រះអគ្គមហេសីនៅទីនោះ ។ ចំណែកព្រះមហាក្សត្រវិក្រមាទិត្យ ទ្រង់យាងត្រឡប់ទៅកាន់ព្រះរាជធានីវិញ ។

រូបទេពនិម្មិតទីប្រាំមួយពោលបន្ថែមថា “មហារាជសូមទ្រង់ជ្រាបចុះ អំពើនេះហើយដែលនាំឲ្យព្រះមហាក្សត្រវិក្រមាទិត្យទ្រង់អាចគង់នៅលើបល្ល័ង្កទិព្វនេះបាន” ។

ព្រះបាទភោជៈ ទ្រង់ជ្រាបច្បាស់ថាទ្រង់គ្មានគុណសម្បត្តិបែបនេះ ទ្រង់ក៏យាងចេញពីបល្ល័ង្កទិព្វនេះទៅ ។

*

*   *

(មានត)

# កំណត់ពិធីប្រវត្តិការណ៍

## ពិធីហែព្រះសារីរិកធាតុ

## ពីប្រទេសសិរីលង្កា មកក្រុងភ្នំពេញ

### ព្រះញាណកោសល ញាណ-ឈឹង រៀបរៀង

---

ពិធីហែព្រះសារីរិកធាតុនេះចាត់ជា ៥ ផ្នែកដូចមានខាងក្រោមនេះ

១ — និយាយពីហេតុដើម

២ — និយាយពីរបៀបតាំងតុសក្ការៈ

៣ — និយាយពីពិធីហែព្រះសារីរិកធាតុ

៤ — និយាយពីកោដ្ឋមាស-ប្រាក់

៥ — និយាយពីកម្មវិធីបុណ្យ

## ១ — ហេតុដើម

កាលពីក្នុងឆ្នាំម្សាញ់បញ្ចស័ក ព. ស. ២៤៩៦ គ. ស. ១៩៥៣ . នោះ ព្រះមហានាយកថេរៈកោះលង្កា បាននិមន្តព្រះសារីរិកធាតុមកដំកល់ទុកនៅវត្តជេតពនក្រុងគយាជាដើម ៗ កាលនោះក្រុមពុទ្ធបរិស័ទអ្នកជ្រះថ្លាជាច្រើននៅដែនកម្ពុជា មានលោក ស៊ឹង-ចាយ-ផ្ទៀង ជាតំណាង បានស្នើសុំឲ្យព្រះថេរៈអង្គនេះ និមន្តព្រះសារីរិកធាតុមកឲ្យយើងខ្ញុំបានមួយអង្គផង ៗ ពីក្រោយឆ្នាំនោះរហូតមក ទើបនឹងសម្រេចថាបានព្រះសារីរិកធាតុកន្លៃអង្គារ ២ កេតខែចេត្រឆ្នាំមមីឆស័ក ព. ស. ២៤៩៧ (១៩ មេសា ១៩៥៤) នេះ ៗ

## ២– របៀបតាំងតុសក្ការៈ

ពិធីរៀបចំតាំងតុសក្ការៈនេះ មុខគួរឲ្យស្ដាយណាស់ ព្រោះវត្តបន្ទូរង្សីមានទីបង្អៀតពេកមិនល្មមនឹងការតាក់តែង ។ សម្បីយ៉ាងនោះក៏ដោយ ក៏គង់លោកសឹង-ថាយ-ង៉ៀង អាចចាត់ការល្មមគួរជាទីជ្រះថ្លាបាន តាមបន្ទាល់ដូចបានដកស្រង់គោលៗខ្លះមករៀបរៀងក្នុងទីនេះ ៖

មុនដំបូងលោកដំណាង មានលិខិតប្រគេន-ជូនដំណឹងទៅខ្មែរនានានៅដែនកូសាំងស៊ីនអំពីរឿងបុណ្យ នៅថ្ងៃអង្គារ ១២ រោចខែចេត្រ ឆ្នាំមមីឆស័ក ព. ស. ២៤៩៧ ត្រូវនឹងថ្ងៃ ១៩ មេសា ឆ្នាំ ១៩៥៥ នេះ ។

លុះដល់កំណត់ថ្ងៃដូចខាងលើនេះហើយ ទើបគណៈកម្មាធិការនាយកចាត់វិធានការដូចមានតទៅគឺ:

ក) រូបខែត្រព្រែកឫស្សី, ខែត្រនេះមានតាំងតុសក្ការៈ ១ នៅខាងទិសនិរតីវត្ត ឈមមុខមកខាងកើត ចារឹកអក្សរធំៗ លើផ្ទាំងសំពត់ពណ៌លឿងជាសញ្ញាឈ្មោះខែត្រនិងថែមពាក្យថា "ជយោ! ព្រះសារីរិកធាតុ" ។ ឯខាងក្នុងសាលសឹងពាសពិតានសំពត់ពីខាងលើ បង់ស្លឹកឈើផ្កាឈើស្រស់ខៀវស្រងាត់ រំលេចដួងភ្លើងអគ្គិសនីភ្លឺព្រោងព្រាត ដូចពន្លឺផ្កាយបញ្ចេញរស្មីតាមស្រទាប់ពពក ។

សសរទាំងឡាយគ្រប់ៗល្វែង សឹងស្រោបស្លឹកឈើស្រស់ហើយពន្ទុចពណ៌ផ្កាក្រដាសក្តីរន្ទាល មុខគួរឲ្យចង់ក្រឡេកមើលមិនដាក់ភ្នែក ហើយតែងទង់ជាតិនិងទង់សាសនា តាមលំដាប់ផ្លូវសសរពីខាងមុខ ។

ផ្ទៃសាលខាងក្រោម គេរៀបតុ-កៅអីគ្រប់ៗ ល្វែងសម្រាប់ទទួលបណ្ដាជន ដែលមកធ្វើសក្ការៈព្រះសារីរិកធាតុនិងសម្រាប់ព្រះសង្ឃគង់ ។

ត្រង់តុតាំងសក្ការៈសឹងរចនាបាក់បេក ភាពបុស្បុកមានស៊ុមទ្វារជា ៤ សណ្ឋាន មានកំពូលស្រួច ហើយតាំងសុទ្ធតែរបស់មានដំឡៃថ្លៃក ៗ ផ្សេងៗ ទោះជារបស់ទំនើបក្ដី របស់បូរាណក្ដី មានពានប៉ាន់តែងរូបចម្លាក់ជាដើម ជារបស់ចុះសម័យ ។ល។

លោកអ្នកបាត់ការដំណាងខែត្រនេះ ប៉ែកខាងព្រះសង្ឃឃើញមានលោកគ្រូ ប្រាក់ ចៅអធិការវត្តពោធិ៍សិរី, លោកគ្រូ មៀច ចៅអធិការវត្តកំពង់ស្ពាន, លោកមហាឧត្តមវិជ្ជា ថាច់-ប្រាជ្ញ; ប៉ែកខាងគ្រហស្ថមានលោក ថាច់លី (ពលបាលត្រី) ភ្នាក់ងាររាជការ យៀកណាមទឹងគណៈកម្មការខែត្រ មានអ្នកអាចារ្យកងជាដើម ជាមួយទឹងក្រុមពុទ្ធបរិស័ទទាំងឡាយ ។

ខ) រូបខែត្រក្រមួនស, ខែត្រនេះ មានតាំងតុសក្ការៈ ១ នៅទិសបស្ចិមត្ដង់ខាងក្រោយសាលាជំនុំរបស់វត្ត; ការរៀបចំស្រដៀងគ្នា មានសរសេរអក្សរធំ ៗ លើផ្ទាំងសំពត់ជាសញ្ញាដូចខែត្រឯទៀតដែរ ។ លោកអ្នកបាត់ការដំណាងខែត្រនេះ ប៉ែកខាងព្រះសង្ឃឃើញមានព្រះគេជព្រះគុណមេគណខែត្រក្រមួនស ទឹងគណៈកម្មការរបស់លោកទាំងព្រះសង្ឃទាំងគ្រហស្ថជាច្រើន ។ល។ ។

គ) រូបខែត្រព្រះត្រពាំង ខែត្រនេះ មានតាំងតុសក្ការៈ ១ ក្នុងសាលាជំនុំរបស់វត្តនៅទិសឧត្តរនៃព្រះវិហារ មានសរសេរអក្សរធំ ៗ

លើផ្ទាំងសំពត់ជាសញ្ញាសម្រាប់ខ្មែរនោះ ។ លោកអ្នកចាត់ការតំ-ណាងខ្មែរ ប៉ែកខាងព្រះសង្ឃឃើញមានព្រះតេជព្រះគុណ អនុគណ វត្តបេកដ៏ជាប្រធាន ទាំងសហការីរបស់លោកគឺ លោកមហាថាប់-ផាត់ វត្តពិសី, លោកគ្រូសូត្រ ស៊ុផាន់, លោកគ្រូសូត្រ ហាស់ វត្តពោធិ-សាលពជ, ប៉ែកខាងគ្រហស្ថឃើញមានអ្នកអាចារ្យ ចៀង សំរប់វត្ត ពិសី ទាំងគណៈកម្មការសម្រាប់ខ្មែរនោះ ។ ល ។ ។

ឃ) រូបខ្មែរត្រពល់លាវ, ខ្មែរនេះ មានតាំងតុសក្ការៈ ១ នៅទិសបស្ចិមនៃព្រះវិហារ មានគណៈកម្មការខ្មែរទាំងព្រះសង្ឃទាំងគ្រហស្ថជាច្រើននាក់ចាត់ចែងបុណ្យមានសរសេរអក្សរធំៗ លើផ្ទាំងសំពត់ជាសញ្ញាសម្រាប់ខ្មែរដូចទីឯទៀតដែរ ។ ល ។ ។

ង) រូបខ្មែរឃ្លាំង, ខ្មែរនេះ មានតាំងតុសក្ការៈ ១ នៅខាងទិសឧត្តរនៃព្រះវិហារ មានសរសេរអក្សរធំៗ ជាសញ្ញាសម្រាប់ខ្មែរដែលលោកអ្នកចាត់ការតំណាងខ្មែរ មានព្រះតេជ-គុណព្រះនាមអ៊ឹម ចៅអធិការវត្តពោធិជាអ្នកបញ្ញាការ ជាមួយទាំងគណៈកម្មការខ្មែរនោះ ។ ល ។ ។

ប) ទីក្រុងព្រៃនគរ, មានពុទ្ធបរិស័ទជាតិកម្ពុជាទាំងយៀកណាម មកពីចំណុះវត្តទាំងបីគឺៈ វត្តចន្ទរង្សី ១, វត្តពោធិរង្សី ១, វត្តជេតពន ១ រួមគ្នាតាំងតុសក្ការៈជាមួយគ្នា នៅខាងទិសទក្សិណនៃព្រះវិហារ ។ មានមន្ទីរឃោសនាការ ១ ទៀតនៅល្វែងជាន់ក្រោមគ្រឹះកុដិចាក់បេតុងល្អស្អាត

នៅខាងត្បូងព្រះវិហារដែរ មន្ទីរនេះមានចារឹកអក្សរធំៗថា "ទីនេះសំរាប់ទទួលសក្ការបូជាចំពោះព្រះសារីរិកធាតុ" ទាំងមានការផ្សាយរឿងផ្សេងៗ គឺ ចែកសៀវភៅ ពត៌មានឯទៀតៗ តាមសំឡេងឧគ្ឃោសនសព្ទ ។ មានគណៈកម្មការទីក្រុងភ្នំពេញ ដែលមានលោក ស៊ីង-ថាយ ឡេង ជាប្រមុខ អ្នកចាត់ចែងការ ។ល។ ។

ឯខាងក្នុងព្រះវិហារថ្មី មានតាំងគ្រឿងសក្ការៈសម្រាប់ដំកល់ព្រះសារីរិកធាតុពីខាងមុខបល្ល័ង្ក ដែលមានទូឈើវិសេសពីរអមសងខាងសម្រាប់ទទួលបារញ្ញាវត្ថុជាគ្រឿងបូជា មានក្រាលកាសទៈគីតខ្មេល ព្រំល្អៗពេញទាំងព្រះវិហារសម្រាប់ព្រះសង្ឃគង់ ។

## ៣ – ពិធីហែព្រះសារីរិកធាតុ

ពីកាលចំណតអាកាសយានឆ្ពោះវត្តបទុមវត្តីភ្នំពេញវេលាម៉ោង ១៣ ថ្ងៃសៅរ៍ ២ កើតខែពិសាខឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៣ មេសា ១៩៥៥) ព្រះនាវទេគ្រៃ នាំព្រះសារីរិកធាតុ ឆ្ពោះមកពីសិង្ហបុរីសំដៅភ្នំពេញ, វេលានោះពួកព្រះសង្ឃបែកខាងក្នុំពេញ មានព្រះវិនយសង្វរកដ-គីង សាស្ត្រាចារ្យសាលាបាឡីជាន់ខ្ពស់, ព្រះគ្រូហ៊ង វត្តសាភាវ៉ន, ព្រះគ្រូ ថាញ់ ចៅអធិការវត្តគេនាពម, ព្រះមេគណ អនុគណ ចៅអធិការឧបជ្ឈាយ៍ ដែលនិមន្តមកអំពីនានាខេត្តនៅកម្ពុជាក្រោមនឹងព្រះសង្ឃចិនយួន ព្រមទាំងពុទ្ធបរិស័ទបព្វជិតគ្រហស្ថទាំងប្រុសស្រី រាប់សែននាក់ ដែលមានគណៈប្រតិភូខេត្តនិងគណៈកម្មការភ្នំពេញ ជាអ្នកត្រួតត្រានាំគ្នារង់ចាំនៅចំណតអាកាសយាន ។

លុះអាកាសយានចតឈប់ស្រួលបួលហើយ ព្រះសង្ឃ ៤ - ១០ អង្គ ចូលទៅទទួលព្រះសារីរិកធាតុនាំហែចេញមក ព្រះសង្ឃច្រើនអង្គឈរតម្រៀបជាពីជួរអមសងខាងផ្លូវ តាំងពីអាកាសយានដកបដល់រថយន្តដែលមានគ្រឿងតាំងគាពបុស្បុកសម្រាប់ដំកល់ហែ មានអាចារ្យពីររូបស្លៀកពាក់សកាន់ក្ងស់បាំងថ្វាយ ។

ឯក្បួនហែដូចមានខាងក្រោមនេះ

ក) ទោចក្រយានយន្ត (ម៉ូតូស៊ីក (motocycle) ៣ គូ ជិះបរសន្សឹមៗ ទៅរងមុខ ។

ខ) រថយន្តតូចៗ បី សម្រាប់គណៈប្រតិភូនិងគណៈកម្មការអ្នកចាត់ក្បួន ។

គ) រថយន្តគាពបុស្បុកដំកល់ព្រះសារីរិកធាតុ មានអាចារ្យបាំងក្ងស់ថ្វាយ ។

ឃ) អ្នកកាន់ផ្ទាំងសំពត់ចារឹកអក្សរសម្រាប់ក្រុមនីមួយៗដែលបានមកហែជាបន្ទោះៗ ។

ង) អ្នកកាន់ទង់សាសនាដើរអមតាំងសងខាងតាមលំដាប់លំដោយគ្នា, ក្រុមព្រះសង្ឃស្បង់ត្រនមស្សការ និមន្តជាប់ជាមួយនឹងរថបុស្បុក, ក្រុមគ្រហស្ថដើរតម្រៀបជាជួរៗហែតាមក្រោយ អ្នកខ្លះកាន់ផ្កាភ្ញី អ្នកខ្លះកាន់ទៀនធូបមានបណ្តោយប្រវែង ៥ គីឡូម៉ែត្រ, រថយន្តតូច ធំជាច្រើនបើកតាមក្រោយ មនុស្សអ្នកឈរមើលក៏ឈរតម្រៀបត្រាគ្រប់ថ្នល់

គ្រប់ប្រកល្អកទាំងស៊ីវិល-ទាហានទាំងមន្ត្រីរាស្ត្រជាតិយៀកណាមនៅក្រុង ព្រៃនគរនោះ ។

បម្លាយពីចំណតអាកាសយានមកអស់រយៈវេលា ៥ ម៉ោង គឺពីម៉ោង ១៣ ដល់ម៉ោង ១៨ ទើបបានដល់វត្តបទុមវតី ។

## ៤– កោដ្ឋដំកល់ព្រះសារីរិកធាតុ

កោដ្ឋនេះ មានពីរប្រភេទគឺ: កោដ្ឋប្រាក់ពីខាងក្រៅ ១ ស្តូបមាសនៅខាងក្នុង ១ ។

កោដ្ឋប្រាក់ មានទំហំ ០ម៉,៥០ បួនជ្រុង មានកំពស់ពីត្រឹមជើងកោសឡើងដល់ក្បាំង ០ម៉,៥០ មានកំពូលពីត្រឹមក្បាំងឡើង ០ម៉,៥០ រួមកំពស់ ១ ម៉ែត្រគត់ មានកញ្ចក់ទាំង ៤ ជ្រុង សណ្ឋានដូចទូធម្មតា, រួមទម្ងន់ប្រាក់ចំនួន ១៨ គីឡូក្រាម, ប្រាក់ទាំងនេះបានមកអំពីសព្វាលង្ការទាំងពួងដែលចាស់គ្រាំគ្រាបាក់បែកខ្លះ ។

ស្តូបមាស ពងមូលមានទំហំ ០ម៉,២០ រស់ត្រង់កណ្តាលមានកំពស់បល្ល័ង្ក ០ម៉,១០ នឹងទំហំបល្ល័ង្ក ០ម៉,១០ គំរបកំពូលមានទំហំ ០ម៉,១០ មានកែវចរណៃមួលភ្ជាប់នឹងកំពូល រួមកំពស់ស្តូបប្រមាណ ០ម៉,៤៥ មានជើងពានមាសស្មុគ្គ ១ តភ្ជាប់នឹងបល្ល័ង្កសម្រាប់ដំកល់ព្រះសារីរិកធាតុ រួមទម្ងន់មាសចំនួន ០គ.ក្រ.៦៣០ មាសទាំងនេះបានមកអំពីសព្វាលង្ការទាំងពួងដែលចាស់គ្រាំគ្រាបាក់បែកខ្លះ ។

កោដ្ឋនេះជាស្នាដៃជាងដែលល្បីឈ្មោះនៅក្រុងភ្នំពេញគឺ លោក

ជា-ប៊ុង ទីប្រឹក្សាជាតិ ក្រសួងព្រឹទ្ធសភា អ្នកចាត់ចែងការ ទាំងបានជួយប្រាក់ជាច្រើនក្នុងការកសាងកោដ្ឋនេះ និងលោក ទៀង-ទៅ ទីទកញ្ញាំចំណានប្រើជាគ្រូរចនាដើមខ្សែផ្តុតលេខ អ្នកតាក់តែងក្បូរក្បាច់ ហើយចាត់ការធ្វើដរាបដល់បានសម្រេច ។

ឯអ្នកម្ចាស់កោដ្ឋ គឺក្រុមពុទ្ធបរិស័ទ បព្វជិតគ្រហស្ថក្នុងខេត្តទាំងឡាយនៅកម្ពុជាក្រោម មានលោកសឺង-ថាយ-ង្វៀន ជាអ្នកផ្ដើម ។ លុះដល់ម៉ោង១៦ថ្ងៃសុក្រ១កើតខែឆ្នាំដដែល ទើបព្រះញាណកោសល ញាណ-ឈឹង ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ លោក ល្វី-ហ៊ុង មេហាងកុមារពេទ្យនៅផ្សារធំថ្មីភ្នំពេញ លោក ហ៊ាប់-ញាណ អតីតចៅហ្វាយស្រុកកិត្តិយសបម្រើរបស់លោក សឺង-ថាយ-ង្វៀន ទៅទទួលយកកោដ្ឋអំពីលោក ជា-ប៊ុង បម្រុងនឹងនាំយកទៅឯព្រៃនគរ ។ ដល់ព្រឹកឡើងម៉ោង ១០ និង ៣០ ថ្ងៃសៅរ៍ ខែ ឆ្នាំដូចខាងលើ ទើបព្រះញាណកោសល, កុមារពេទ្យ, ព្រះមហាប៉ាង-ខាត់ បាននាំកោដ្ឋនោះឆ្ពោះទៅព្រៃនគរ ។ ម៉ោង១៨ និង ៣០ បាននិមន្ត-អញ្ជើញទៅដល់វត្តចន្ទរង្សី ជាបន្ទាប់វេលាដែលគេហែព្រះសារីរិកធាតុមកដល់វត្តនេះដែរ ។ បណ្ដាក្រុមពុទ្ធបរិស័ទជាច្រើនពាន់នាក់រង់ទន្ទឹងមើលផ្លូវ លុះដឹងថាកោដ្ឋមកដល់ហើយ ក៏មានសេចក្ដីសោមនស្សរីករាយឥតឧបមា អ្នកខ្លះទះដៃស្រែកហ៊ោ អ្នកខ្លះទទួលសាធុ! អ្នកខ្លះស្រែកជយោ! ប្រគេនស័ព្ទសាធុការពរអឺងកងចំពោះលោកទាំង ៣ រូប

ដូចមានទាមទារលើ រួចហើយនាំឡើងទៅកាន់ព្រះវិហារ ដំកល់ព្រះសារីរិកធាតុក្នុងគ្រានោះឯង ។

## ៥ — និយាយអំពីកម្មវិធីបុណ្យ

ថ្ងៃទី ១: នៅថ្ងៃ ៦ ᧡ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២២-មេសា ១៩៥៥) លោកស៊ឹង ថាយ-ឆៀង ឲ្យប្រជុំពុទ្ធបរិស័ទនៅវត្តបទុមវង្ស ព្រៃនគរ (វៃកកាតព្ពកិច្ច) ។

ថ្ងៃទី ២: នៅថ្ងៃ ៧ ᧡ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៣-៤-៥៥) ។ ម៉ោង ១៣ ទទួលព្រះសារីរិកធាតុនៅទីធ្លាចំណតអាកាសយានព្រៃនគរ ។ ម៉ោង ១៨ វែហព្រះធាតុទក្សិណព្រះវិហារវត្តបទុមវង្ស ។ ម៉ោង ១៨, ៣០ អញ្ជើញគោដ្ឋឡើងកាន់ព្រះវិហារដំកល់ព្រះសារីរិកធាតុ, បន្ទាប់មកព្រះនាវទត្ថេរ លោករៀបចប់ប្រវត្តដំណើរមកកាន់ទីក្រុងព្រៃនគរ ។ ម៉ោង ១៩ បើកឲ្យការសឲ្យពុទ្ធបរិស័ទចូលធ្វើគារវកិច្ចចំពោះព្រះសារីរិកធាតុ ។ ម៉ោង ២០,៣០ គណកម្មការនិមន្តព្រះនារទត្ថេរ សំដែងធម៌ទេសនាជាភាសាអង់គ្លេស, ព្រះមហាប៉ាង-ខាត់ ក្រមជំនុំព្រះត្រៃបិដកប្រែជាភាសាខ្មែរ, ភិក្ខុ គូ-ធឿង ប្រែជាភាសាយៀមណាម ដល់ម៉ោង ២២ អធ្រាត្រទើបចប់ ។ បន្ទាប់មកពួកអ្នកភ្លេងប្រគំតូរ្យតន្ត្រី ល្បែងកំសាន្ត ល្បែងផ្សេងៗ ច្រើនប្រភេទដរាបដល់ភ្លឺ ។

ថ្ងៃទី ៣: នៅថ្ងៃ ១ ᧢ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៤-៤-៥៥) ។ ម៉ោង ៨ ប្រជុំពុទ្ធបរិស័ទដង្ហែព្រះសារីរិកធាតុ

មួយអង្គទៀតពីវត្តចន្ទរង្សីទៅកាន់វត្តព្រះសង្ឃចិន  ប៉ែកខាងមហាយាន នៅផ្សារធំ (ចឺ-ឡើង (Chò-Lớn) ព្រៃនគរ ។ ម៉ោង ១៣ ១៤ ពុទ្ធបរិស័ទចូលធ្វើការកិច្ចទៀត ។ ម៉ោង ១៦ គណៈកម្មការនិមន្តព្រះគ្រូ ជាញ់ ចៅអធិការវត្តរតនារាម ភ្នំពេញ សំដែងធម៌ទេសនាជាភាសា យៀកណាម ប្រែចេញជាភាសាកម្ពុជា, ដល់ម៉ោង ១៨ ទើបចប់ ។ ម៉ោង ១៩ ប្រគេនគេសជ្ជៈព្រះសង្ឃតាមលំដាប់សាលបុណ្យ ។ ម៉ោង ២០,៣០ គណៈកម្មការនិមន្តព្រះញាណកោសល ញាណ-ឈឺន សំដែងធម៌ទេសនាអំពីប្រវត្តិព្រះសារីរិកធាតុនឹងព្រះធាតុខាគធំ-តូច របស់ព្រះគោតមបរមគ្រូជាអម្ចាស់នៃយើង, រាង៤០នាទីទើបចប់ធម៌ទេសនា ។ ម៉ោង ២១,៣០ ព្រះមហាប៉ាង-ខាត់ សំដែងធម៌ទេសនាតៗទៀត អំពីពុទ្ធគុណនឹងចរិយារបស់ព្រះអង្គដកបដល់យប់ជ្រៅ។ បន្ទាប់ពីនោះពួកអ្នកល្បែងគ្រប់ប្រភេទលេងមហោស្រពជាដើម ដកបដល់ភ្លឺដូចយប់មុន ។ ។

ថ្ងៃទី ៤ នៅថ្ងៃ ២ ៤ ៦ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៥-៤-៥៥) ។ ម៉ោង ១០,៣០ ព្រះញាណកោសល, ព្រះមហាប៉ាង-ខាត់ ព្រះគ្រូ ជាញ់ ចៅអធិការ វត្តរតនារាម, និងកុមារពេទ្យលូវ ហុង វិលត្រឡប់ទៅភ្នំពេញវិញ ។ វេលាយប់នោះ ព្រះវិន័យសង្ឃ រាជ-គឹង ព្រះគ្រូ ភាង នៅចាត់ការបុណ្យតទៅ មួយយប់ទៀត ។ លុះដល់ថ្ងៃអង្គារ ៥ កើតខែពិសាខឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ (២៦-៤-៥៥) ទើបជូនសម្រេចកិច្ច ។ រឿងហែព្រះសារីរិកធាតុនេះ នៅមានបញ្ហាសុកស្មាញ

បន្ស៊ែតជាសេចក្ដីវិសេសជាងនេះច្រើនណាស់ ប៉ុន្តែអ្នកនិពន្ធដកស្រង់យកតែគោល ៗ មកចារិកទុកក្នុងទីនេះជាសេចក្ដីសង្ខេបដើម្បីនឹងឲ្យកើតសទ្ធាជ្រះថ្លាត្រឹមប៉ុណ្ណេះ ។

មុននឹងបញ្ចប់ សូមសរសើរភ្នាក់ងារប្រតិភូស្ថានប្រទេសកម្ពុជាប្រចាំនៅក្រុងព្រៃនគរដែលមានលោក ស៊ុំ ហៀង អតីតសេនាបតីជាប្រមុខ នឹងលោកស៊ឹង ថាយ-ង៉ៀង តំណាងប្រជាជនខ្មែរកម្ពុជាក្រោម លោកទាំងនេះ អាចពុះពារចាត់ការបុណ្យរបៀបសាសនាក្នុងចំណោមប្រទេសយៀកណាមឥតឲ្យមានរនុស្ថាន នឹងត្រូវត្រាពុទ្ធបរិស័ទរាប់សែននាក់ឥតមានមោះមៃឡើយ ។

សូមថ្វាយស័ព្ទសាធុការពរចំពោះបរមក្សត្រប្រទេសទាំងពីរ នឹងរដ្ឋាភិបាលរបស់ទ្រង់ឲ្យបានគង់នៅជាស្ថាពរអស់កាលដ៏លង់ ។ សូមឲ្យពុទ្ធបរិស័ទទាំងបព្វជិត គ្រហស្ថ នាចំណោមហែព្រះសារីរិកធាតុនេះជាដើម ឲ្យបានសម្រេចផលជាន់ខ្ពស់ត្រូវតាមប្រាថ្នាក្នុងឥធលោកនឹងបរលោក សូមមានសម្បត្តិព្រះនិព្វានជាអវសាន ។

# របៀបសិក្សានៃសាលាបាលីជាន់ខ្ពស់

## ដែលផ្លាស់នាមជា "គ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធសាសនា"

## ពុទ្ធសាសនបណ្ឌិត្យ ស្រង់ចាកព្រះរាជក្រឹត្យ

---

តាមព្រះរាជក្រឹត្យលេខ ២៦៥ ន.ស ចុះថ្ងៃទី ១៨ ឧសភា ឆ្នាំ ១៩៥៥ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ត្រាស់បង្គាប់ដូចមានខាងក្រោមនេះ ៖

ដើម្បីផ្សព្វផ្សាយមធ្យមសិក្សា នៃព្រះពុទ្ធសាសនា ហើយនឹងបណ្តុះបណ្តាលសិស្សទាំងឡាយ ឲ្យចូលទៅរៀននៅមហាវិទ្យាល័យពុទ្ធសាសនា របៀបរៀបចំនឹងរបបសិក្សានៃសាលាបាលីជាន់ខ្ពស់ ដូចដែលមានកំរិតហើយ តាមព្រះរាជក្រឹត្យលេខ ១០៣ ន.ស. ចុះថ្ងៃទី ១៧ មីនា ១៩៥២ ត្រូវកែប្រែនឹងបំពេញដូចតទៅ:

សាលាបាលីជាន់ខ្ពស់ នឹងមាននាមថា "គ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធសាសនា" ។

យានភាសាគឺភាសាជាតិ ។ របៀបបង្រៀនសព្វយ៉ាង លើកលែងតែជីវភាសាចេញ ត្រូវបង្រៀនជាខ្មែរ ។

ថិរវេលា នៃកិច្ចសិក្សាមានកំណត់ ៤ ឆ្នាំ ។ លក្ខខណ្ឌនៃការចូលរៀននឹងការប្រឡងពិនិត្យ ដែលមានធ្វើនៅចុងឆ្នាំទី ៤ នៅតែប្រតិបត្តិតាមព្រះរាជក្រឹត្យដូចខាងលើ ដោយគ្រាន់តែយោលទៅរកការកែប្រែដែលមានបញ្ញត្តិក្នុងប្រការដូចតទៅ ។

ក្នុងករណីដែលសិស្សបានប្រឡងជាប់នៅវេលាក្រោយឆ្នាំទី ៤ នោះ

ការសិក្សាត្រូវមានការបញ្ចប់វិជ្ជា ដោយសញ្ញាប័ត្រមធ្យមសិក្សានៃពុទ្ធ-សាសនា ។

ប៉ុន្តែសញ្ញាប័ត្រ នឹងត្រូវចេញឲ្យអ្នកប្រឡងជាប់បាន លុះត្រាតែបានអប់រំបន្ថែមមួយឆ្នាំទៀត នៅក្នុងរយៈវេលានេះ សិស្សដែលប្រឡងជាប់ ត្រូវតែបំពេញវិជ្ជាខាងការបង្ហាត់បង្រៀន ឬខាងរបៀបរៀបចំសាលារៀនទៀត ។

ការហាត់ធ្វើការនេះ មិនមែនតម្រូវដល់សិស្សអ្នកប្រឡងជាប់ ដែលប្រាថ្នាបន្តវិជ្ជាមហាវិទ្យាល័យនៃពុទ្ធសាសនាឡើយ ។

វិញ្ញាសាទាំងឡាយនៃការប្រឡងប្រជែង ដែលបានចែងទុកក្នុងប្រការ ១៥ នៃព្រះរាជក្រឹត្យខាងលើនេះ ត្រូវបន្ថយចំនួនមកនៅត្រឹមតែ ៤ មុខវិញ ៖

| | មេគុណ | កំណត់ពេល |
|---|---|---|
| ទី ១ – សរសេរតាមសូត្រជាភាសាខ្មែរ ចំនួន ១៥ បន្ទាត់ . . . . . . | ២ | ១ ម៉ោង |
| ទី ២ – ប្រែអត្ថបទពីបាលីមកជាខ្មែរចំនួន ១៥ បន្ទាត់ ទៅ ២០ បន្ទាត់ ដកស្រង់ពីគម្ពីរអដ្ឋកថាធម្មបទ . . . . . . | ៣ | ២ – |
| ទី ៣ – បញ្ហាវិន័យពីរគឺ ១ សម្រាប់ភិក្ខុ, ១ សម្រាប់សាមណេរ . . . . . | ២ | ២ – |
| ទី ៤ – ការគិតបត្តិធលេខ . . . . . . | ២ | ២ – |

មុខវិជ្ជាបង្រៀនមានកំណត់ទុកក្នុងតារាងដូចខាងក្រោមនេះ៖

| មុខវិជ្ជាបង្រៀន | | ចំនួនម៉ោងរាល់សប្តាហ៍ |
|---|---|---|
| ឆ្នាំទី ១ – ភាសាប្រចាំថ្នាក់ | បាលី | ៨ ម៉ោង |
| | ខ្មែរ | ១ – |
| ដីវភាសា | បារាំង ជាភាគតូចកិច្ច (តាមរើស) | ៤ – |
| | អង់គ្លេស ឥតបង្ខំ (តាមរើស) | ២ – |
| ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ | ប្រវត្តិសាស្ត្រ | ២ – |
| | ភូមិសាស្ត្រ | ១ – |

| | ចំនួនម៉ោងរាល់សប្តាហ៍ |
|---|---|
| គណិតសាស្ត្រ | ៥ ម៉ោង |
| វិទ្យាសាស្ត្រ ធម្មជាតិនិងអនាម័យ | ២ – |
| បំណេះវិជ្ជាទូទៅ: លោកនីតិ | ១ – |

| | | |
|---|---|---|
| ឆ្នាំទី ២ – ភាសាប្រចាំថ្នាក់ | បាលី | ៦ – |
| | សំស្ក្រឹត | ៣ – |
| | ខ្មែរ | ១ – |
| ដីវភាសា | បារាំង ឬ ជាភាគតូចកិច្ច (តាមរើស) | ៤ |
| | អង់គ្លេស ឥតបង្ខំ | ២ |
| ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ | ប្រវត្តិសាស្ត្រ | ១ – |
| | ភូមិសាស្ត្រ | ១ – |
| គណិតសាស្ត្រ | | ៤ – |

| មុខវិជ្ជាបង្រៀន | | | ចំនួនម៉ោងរាល់សប្តាហ៍ |
| --- | --- | --- | --- |
| | វិទ្យាសាស្ត្រ | ធម្មជាតិនិងអនាម័យ | ១ ម៉ោង |
| | | វិទ្យាសាស្ត្ររូបនិយម | ២ – |
| | | គីមី | ១ – |
| ឆ្នាំទី ៣ — | ភាសាប្រចាំជាតិ | បាលី | ៦ – |
| | | សំស្ក្រឹត | ៣ – |
| | | ខ្មែរ | ១ – |
| | ជីវភាសា — បារាំងឬ | ជាកាតព្វកិច្ច (តាមរើស) | ៥ – |
| | ជីវភាសា — អង់គ្លេស | ឥតបង្ខំ (តាមរើស) | ២ – |
| | ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ | ប្រវត្តិសាស្ត្រ | ១ – |
| | | ភូមិសាស្ត្រ | ១ – |
| | គណិតសាស្ត្រ | | ៤ – |
| | វិទ្យាសាស្ត្រ | ធម្មជាតិនិងអនាម័យ | ១ – |
| | | វិទ្យាសាស្ត្ររូបនិយម | ១ – |
| | | គីមី | ១ – |
| | បំណេះវិជ្ជាទូទៅ៖ សាសនប្រវត្តិ | | ១ ម៉ោង |
| ឆ្នាំទី ៤ — | ភាសាប្រចាំជាតិ | បាលី | ៥ – |
| | | សំស្ក្រឹត | ៣ |
| | | ខ្មែរ | ១ – |

| មុខវិជ្ជាបង្រៀន | | | ចំនួនម៉ោងរាល់សប្តាហ៍ |
|---|---|---|---|
| ជីវភាសា | បារាំងឬ | ជាភាគតព្វកិច្ច (តាមជ្រើស) | ៤ – |
| | អង់គ្លេស | ឥតបង្ខំ (តាមជ្រើស) | ២ – |
| ប្រវត្តិសាស្ត្រ-ភូមិសាស្ត្រ | | ប្រវត្តិសាស្ត្រ ...... | ២ ម៉ោង |
| | | ភូមិសាស្ត្រ ........ | ១ – |
| គណិតសាស្ត្រ ............... | | | ៤ – |
| វិទ្យាសាស្ត្រ ..... | | ធម្មជាតិនិងអនាម័យ .... | ១ – |
| | | វិទ្យាសាស្ត្ររូបនិយម .... | ១ – |
| | | គីមី ........... | ១ – |
| បំណេះវិជ្ជាទូទៅ .... | | លោកនីតិ ......... | ១ – |
| | | អរិយធម៌ខ្មែរ (សិល្បខ្មែរ) | ១ – |

កម្មវិធីពិស្តារសម្រាប់ឆ្នាំសិក្សានីមួយៗ នឹងសម្រាប់មុខវិជ្ជាបង្រៀននីមួយៗ នឹងត្រូវរៀបរៀងដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងធម្មការ តាមសេចក្តីស្នើសុំនៃគណកម្មការពិសេស ១ ក្រុម ដែលបានតែងតាំងឡើងដោយប្រកាសនៃរដ្ឋមន្ត្រីក្រសួងធម្មការដែរ ។

វិញ្ញាសាសរសេរនៃការប្រឡងពិនិត្យយកសញ្ញាប័ត្រ ដែលមានចែងទុកក្នុងប្រការ ២១ នៃព្រះរាជក្រឹត្យលេខ ១០៣ ន.ស. ចុះថ្ងៃទី ១៧ មីនា ១៩៥២ នោះ ត្រូវមានកំរិតត្រឹម ៧ ដូចតទៅ ។

| លេខរៀង | វិញ្ញាសា | មេគុណ | រយៈពេល |
|---|---|---|---|
| ១ – | ប្រែពីបាលីមកជាខ្មែរ ឬពីខ្មែរទៅជាបាលី | ៣ | ២ ម៉ោង |

| លេខរៀង វិញ្ញាសា | មេគុន | រយៈពេល |
|---|---|---|
| ២ – ប្រែពីសំស្ក្រឹតមកជាខ្មែរ ឬពីខ្មែរទៅជាសំស្ក្រឹត . . . . . . . . . . . . . . . . . . | ២ | ២ ម៉ោង |
| ៣ – ប្រែពីអង់គ្លេស ឬបារាំងមកជាខ្មែរ ឬពីខ្មែរទៅជាអង់គ្លេសឬបារាំង . . . . . . . . | ២ | ២ – |
| ៤ – អធិប្បាយអំពីលទ្ធិព្រះពុទ្ធសាសនា . . . (អភិធម្មឬវិន័យ) . . . . . . . . . . . . . . . . | ៣ | ៣ – |
| ៥ – ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ . . . . . . | ២ | ២ – |
| ៦ – គណិតសាស្ត្រ . . . . . . . . . . . . . . | ២ | ២ – |
| ៧ – វិទ្យាសាស្ត្រ . . . . . . . . . . . . . . . | ២ | ២ – |

លុះប្រឡងពិនិត្យរួចហើយ គណៈកម្មការត្រូវផ្ញើបញ្ជីរាយឈ្មោះ បេក្ខជនម្នាក់ៗដែលប្រឡងហើយ ទៅសុំសេចក្ដីយល់ព្រមរដ្ឋមន្ត្រីក្រសួងធម្មការ ។ បេក្ខជនដែលបានពិន្ទុបំនួនទាំងអស់ត្រឹម ១៦០ ឬលើសពីនេះទុកជាបានប្រឡងជាប់ ។

សញ្ញាប័ត្រដូចមានចែងទុកក្នុងប្រការ ២៣ នៃព្រះរាជក្រឹត្យដែលបានចុះហត្ថលេខាលើត្រូវចុះនិទ្ទេសតាមចំនួនពិន្ទុដូចតទៅនេះ ៗ

| | | | | |
|---|---|---|---|---|
| ពីពិន្ទុ | ១៦០ | ទៅ | ១៧៦ | មធ្យម |
| ” | ១៧៧ | ទៅ | ២០៨ | ល្អបង្គួរ |
| ” | ២០៩ | ទៅ | ២៤០ | ល្អ |

ពីពិន្ទុ ២៤១ ទៅ ២៧២ ល្អណាស់

ពី ២៧៣ ឡើងទៅ ល្អវិសេស

បេក្ខជនអាចសុំអនុញ្ញាតនៅរៀនក្នុងថ្នាក់ទី ៤ មួយឆ្នាំតទៅទៀតបាន ដោយសេចក្ដីយល់ព្រមពីបាងហ្វានផង ដើម្បីនឹងបានប្រឡងចេញនៅឆ្នាំតទៅ ។

បេក្ខជនដែលប្រឡងធ្លាក់ អាចសុំចូលទៅប្រឡងទៀតបាន នៅពេលបើកសម័យប្រឡងតទៅ ក្នុងឋានៈជាបេក្ខជនស្វ័យវិន ។

របបសិក្សា ដែលកំណត់ក្នុងព្រះរាជក្រឹត្យនេះ នឹងចូលជាធរមានគិតពីថ្ងៃទី ១ កុម្ភៈ ១៩៥៥ តទៅ ។

ប៉ុន្តែសិស្សថ្នាក់ទី ២ ទី ៣ នឹងទី ៤ (ឆ្នាំ ១៩៥៥ - ៥៦) នឹងត្រូវបន្តវិជ្ជាទៅតាមរបបចាស់រហូតដល់អវសាននៃការសិក្សារបស់ខ្លួន ។